សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការធ្វើអស្សាមិករណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **អ៊ុំ ម៉ែនពិសិដ្ឋ**
កញ្ញា **វ័ត្ត បុប្ផាម៉ូនិច**

សាស្ត្រាចារ្យណែនាំ
លោក បណ្ឌិត **អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# សេចក្ដីថ្លែងអំណរគុណ

ក្រុមរបស់ខ្ញុំមានឈ្មោះ **អ៊ុំ ប៉ែនពិសិដ្ឋ** និងឈ្មោះ **រ័ត្ន បុប្ផាម៉ូនិច** ដែលជានិស្សិតបរិញ្ញាបត្រ នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសំដែងនូវការដឹងគុណ និងការគោរពយ៉ាងជ្រាលជ្រៅចំពោះ៖

អ្នកម្ដាយ **អ៊ុំ សុផន** និងលោកឪពុក **កើត ស៊ីដេន** អ្នកម្ដាយ **ជា ណូរ៉ា** របស់ក្រុមខ្ញុំ ដែលបានទំនុកបម្រុង ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ផ្ដល់ភាពកក់ក្ដៅ ផ្ដល់កម្លាំងចិត្ត និងផ្ដល់ធនធានឲ្យកូនបានសិក្សារៀនសូត្រដល់សព្វថ្ងៃ។

ឯកឧត្ដម **លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងថ្នាក់ដឹកនាំសាកវិទ្យាល័យទាំងអស់ ដែលបានផ្ដល់ឱកាសឲ្យក្រុមរបស់ខ្ញុំបានសិក្សារៀនសូត្រនៅសាកលវិទ្យាល័យនេះ។

ជាពិសេស លោកសាស្ត្រាចារ្យ បណ្ឌិត **អ៊ុន សកក្កដា** ដែលបានចំណាយកម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃផ្ដល់ពុទ្ធិល្អៗ ដាស់តឿន ផ្ដល់ឯកសារជំនួយ និងណែនាំវិធីសាស្ត្រផ្សេងៗក្នុងដំណើរការសិក្សាស្រាវជ្រាវរបស់ក្រុមខ្ញុំ ក៏ដូចជា ត្រួតពិនិត្យ និងផ្ដល់យោបល់កែលំអរចំពោះចំណុចខុសឆ្គងដែលកើតមានជារឿយៗ។

ក្រៅពីលោកសាស្ត្រចារ្យណែនាំ ក៏នៅមានសិស្សច្បង ដែលបានចំណាយពេលវេលាជួយឆ្លើយសំនួរ ពន្យល់បន្ថែម និងផ្ដល់ជាឯកសារពិគ្រោះ សម្រាប់ចំនុចណាដែលក្រុមខ្ញុំនៅមានភាពស្រពិចស្រពិល។

រួមទាំង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកនៅគ្រប់ការិយាល័យទាំងអស់ដែលបានផ្ដល់ភាពប្រាស្រ័យទាក់ទងល្អ និងបង្កការសិក្សាស្រាវជ្រាវរបស់ក្រុមខ្ញុំដំណើរការបានដោយរលូន។

ក្រុមខ្ញុំ សូមជូនពរដល់អ្នកទាំងអស់គ្នានូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កើតមាននៅក្នុងជីវិត និងទទួលបានភាពជោគជ័យរាល់ភារកិច្ច។

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចលើមុខជំនាញនីតិសាស្ត្រ រយៈពេល ៤ឆ្នាំ នៅក្នុងឆ្នាំបញ្ចប់ការសិក្សា និស្សិតមួយចំនួនតម្រូវឲ្យសរសេរសារណា និងនិស្សិតមួយចំនួនទៀតតម្រូវឲ្យប្រលងបញ្ចប់បរិញ្ញាបត្រ។ ចំពោះ ក្រុមរបស់ខ្ញុំជានិស្សិតសរសេរសារណាបញ្ចប់ការសិក្សា បន្ទាប់ពីពិភាក្សាជាមួយមិត្តរួមក្រុម និងទទួលការណែនាំពីលោកសាស្ត្រាចារ្យ ***អ៊ុន សកក្កដា*** ក្រុមរបស់ខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទសារណាមួយមានគឺ "***ការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា***"។

មូលហេតុដែលធ្វើឲ្យក្រុមរបស់ខ្ញុំជ្រើសរើសយកប្រធានបទនេះ ដោយសារតែការធ្វើអស្សាមិករណ៍មានសារៈសំខាន់រួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ ក្នុងគោលបំណង និងគោលដៅបម្រើដល់ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ឲ្យកាន់តែរីកចម្រើន។ ផ្ទុយទៅវិញប្រជាពលរដ្ឋកម្ពុជាផ្ទាល់ និងសិស្សនិស្សិតមួយចំនួន ពុំបានយល់ច្បាស់អំពីអស្សាមិករណ៍នេះឡើយ ក៏ព្រោះតែច្បាប់ស្តីពីអស្សាមិករណ៍ពុំមានការផ្សព្វផ្សាយទូលំទូលាយ ជាហេតុបង្កឲ្យប្រជាពលរដ្ឋមិនបានយល់ដឹងអំពីអត្ថប្រយោជន៍នៃអស្សាមិករណ៍ និងយល់ច្រឡំថាការធ្វើអស្សាមិករណ៍គឺជាការដកហូតដោយបង្ខំនូវសិទ្ធិស្របច្បាប់ទៅលើអចលនវត្ថុ។

គោលបំណងសំខាន់មួយទៀត គឺចង់ឲ្យសាធារណៈជន សិស្ស និស្សិតជំនាន់ក្រោយបានយល់ដឹងទាក់ទងនឹងនីតិវិធីក្នុងការធ្វើអស្សាមិករណ៍នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាបញ្ហាប្រឈមដែលកើតចេញពីការធ្វើអស្សាមិករណ៍ និងដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនោះ។

ក្រុមរបស់ខ្ញុំជឿជាក់ថាស្នាដៃនេះអាចនឹងមានកំហុសខ្លះ ឬ នៅមានភាពខ្វះចន្លោះត្រង់កន្លែងណាមួយជាក់ជាពុំខាន ដូចនេះ ក្រុមរបស់ខ្ញុំរីករាយស្វាគមន៍រាល់មតិរិះគន់ពីសំណាក់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោក លោកស្រី និងមិត្តអ្នកអាន ដើម្បីស្ថាបនាក្នុងគោលបំណងឲ្យសៀវភៅសារណាបញ្ចប់ការសិក្សានេះកាន់តែល្អប្រសើរជាងមុន។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១ មូលហេតុនៃការធ្វើអស្សាមិករណ៍** ........................................................ ៤

**១.១. សញ្ញាណទូទៅ** ........................................................ **៥**

១.១.១. គោលការណ៍នៃការធ្វើអស្សាមិករណ៍ ........................................................ ៦

១.១.២. អស្សាមិករណ៍ពិសេស ........................................................ ៨

១.១.៣. យន្តការនៃការធ្វើអស្សាមិករណ៍ ........................................................ ៩

**១.២. នីតិវិធីនៃអស្សាមិករណ៍** ........................................................ **១០**

១.២.១. នីតិវិធីមុនការធ្វើអស្សាមិករណ៍ ........................................................ ១១

ក. គម្រោង ........................................................ ១១

ខ. ការប្រកាសគម្រោង ........................................................ ១៣

១.២.២. នីតិវិធីក្នុងពេលធ្វើអស្សាមិករណ៍ ........................................................ ១៤

ក. ការដកហូតអចលនវត្ថុ ........................................................ ១៥

ខ. ការអនុវត្តគម្រោង ........................................................ ១៥

១.២.៣. ការទូទាត់សំណងនៃអស្សាមិករណ៍ ........................................................ ១៦

ក. គោលការណ៍នៃការផ្តល់សំណង ........................................................ ១៧

ខ. នីតិវិធីនៃការផ្តល់សំណង -------------------------------------------------------- ១៨

**ជំពូកទី២ វិវាទពាក់ព័ន្ធនៃអស្សាមិករណ៍** ........................................................ ២១

**២.១. បញ្ហាប្រឈម** ........................................................ **២១**

២.១.១. បញ្ហាប្រឈមរវាងរដ្ឋ និងទ្រព្យសម្បត្តិរបស់រដ្ឋ ........................................................ ២២

២.១.២. បញ្ហាប្រឈមរវាងរដ្ឋ នឹងប្រជាពលរដ្ឋ....................................................២៣
**២.២. ការដោះស្រាយវិវាទអសុរោមិករណ៍..................................................................២៥**
២.២.១. ការដោះស្រាយក្រៅប្រព័ន្ធតុលាការ .......................................................២៦
២.២.២. ការដោះស្រាយក្នុងប្រព័ន្ធតុលាការ ........................................................២៨
**សេចក្តីសន្និដ្ឋាន**.....................................................................................................៣១
**អនុសាសន៍**..........................................................................................................៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ក្រោយពីដើបរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលជារបបសាហាវយង់ឃ្នងមួយដោយគ្មានការគោរពសិទ្ធិមនុស្ស គ្មានការអភិវឌ្ឍ គ្មានការរីកចម្រើន និងជារបបដែលសម្លាប់មនុស្សរង្គាលផងដែរនោះ យើងឃើញថាប្រទេសកម្ពុជាបានធ្វើការវិវត្តន៍ខ្លួនទៅជាប្រទេសមួយដែលប្រកបដោយការគោរពសិទ្ធិមនុស្ស មានការអភិវឌ្ឍ និងមានការរីកចម្រើន ដើម្បីជាផលប្រយោជន៍រួម ជាពិសេសផលប្រយោជន៍ជាតិ។ នៅក្នុងចំណោមការអភិវឌ្ឍទាំងអស់ មានការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈជាច្រើន សម្រាប់បំពេញតម្រូវការរបស់ជាតិក៏ដូចជាសង្គមទាំងមូល ដោយក្នុងនោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាអ្នកដឹកនាំ និងត្រួតពិនិត្យនូវរាល់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធ្វើឲ្យដំណើរការនៃការសាងសង់ប្រព្រឹត្តឡើងដោយស្របទៅនឹងច្បាប់។ ដើម្បីទទួលបានការជ្រាបច្បាស់អំពីតួនាទីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់នោះ នឹងធ្វើការរៀបរាប់អំពីប្រវត្តិសង្ខេបមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទនេះ។ ដោយចាប់តាំងពីក្រោយការរំដោះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ការិយាល័យសំណង់ ត្រូវបានដាក់នៅក្រោមចំណុះរបស់មន្ទីរផែនការ មន្ទីរឧស្សាហកម្ម ក្រោយមកក្នុងឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលនីតិកាលទី១នៃរដ្ឋសភា អគ្គនាយកដ្ឋាននេះ ស្ថិតនៅក្រោមចំណុះក្រសួងសាធារណការ និងដឹកជញ្ជូន។ បន្ទាប់មក ទើបរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីទទួលបន្ទុកប្រមូលផ្តុំការងារទាំងអស់ឲ្យមានស្ថេរភាព និងស្ថិតក្រោមស្ថាប័នតែមួយ។ នៅចុងឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យសាងសង់អាគារថ្មី ដោះស្រាយបញ្ហាន្លែងធ្វើការជូនមន្ត្រីរាជការ ដែលមានកំណើនជាលំដាប់ស្របតាមសំណូមពរការងារកាន់តែកើនឡើង ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៨ និងចូលជាធរមាននៅឆ្នាំ១៩៩៩[១]។ អាជ្ញាធរមានសមត្ថកិច្ចចំពោះផ្នែកនគរូបនីយកម្ម រួមមាន គណៈកម្មាធិការជាតិរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រុងភ្នំពេញ និងជាចុងក្រោយគឺ អនុគណៈកម្មាធិការ[២]។

[១] http://www.mlmupc.gov.kh/?page=detail&menu1=215&menu2=263&ctype=article&id=263&lg=kh ចូលមើលថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៧

[២] សៀវភៅ នីតិនគរូបនីយកម្ម របស់លោកបណ្ឌិត អ៊ុន សកក្កដា ជំពូកទី៤ ទំព័រទី១៣០

ប្រទេសកម្ពុជាប្រកាន់របបប្រជាធិបតេយ្យ ក្នុងការអភិវឌ្ឍប្រទេសជាតិឲ្យកាន់តែមានការរីកចម្រើនទៅមុខ រាជរដ្ឋាភិបាលបានខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាច្រើន ដើម្បីបំពេញតម្រូវការរបស់ម្ចាស់ប្រទេស និងតម្រូវការរបស់សង្គមជាតិទាំងមូល ម្យ៉ាងទៀត ដើម្បីឲ្យប្រទេសជាតិអាចចូលចុះចំណោមសង្គមអន្តរជាតិ និងបង្ហាញឲ្យគេឃើញថាប្រទេសកម្ពុជាពិតជារីវត្តន៍ខ្លួនបានពិតមែន។ ការបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធនីមួយៗ សុទ្ធសឹងតែត្រូវការជ្រើសរើសទីតាំងឲ្យបានល្អ ទោះបីទីតាំងនោះត្រូវបានគេកាន់កាប់រួចហើយក៏ដោយក៏រាជរដ្ឋាភិបាលត្រូវតែយកទីតាំងនោះមកធ្វើការកសាង ដើម្បីអភិវឌ្ឍផងដែរ។ ទោះបី ប្រទេសកម្ពុជាកាន់តែមានការអភិវឌ្ឍទៅមុខពិតមែន បើយើងក្រឡេកមកមើលការកាន់កាប់សិទ្ធិរបស់ប្រជាពលរដ្ឋទៅលើអចលនទ្រព្យវិញ គឺត្រូវបានរំលោភទៅលើសិទ្ធិរបស់ពួកគេយ៉ាងខ្លាំង។ ការរំលោភសិទ្ធិពីសំណាក់រាជរដ្ឋាភិបាលទៅលើប្រជាពលរដ្ឋនេះហើយ ជាកត្តាមួយបង្កឲ្យមានការប្តឹងតវ៉ាយ៉ាងខ្លាំងខ្លា ពីសំណាក់ប្រជាពលរដ្ឋដោយសារតែការដកហូតយកនូវសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់ និងរស់នៅលើអចលនវត្ថុរបស់ពួកគេនោះ។ មិនត្រឹមតែ ប្រជាពលរដ្ឋដែលជាកម្មសិទ្ធិករឯកជនប៉ុណ្ណោះទេដែលមានបញ្ហា ប៉ុន្តែប្រជាពលរដ្ឋដែលជាសហកម្មសិទ្ធិករ ដូចជាសហគមន៍ជនជាតិដើមភាគតិច ក៏បានជួបប្រទះនូវបញ្ហាអស្សាមិករណ៍នេះដែរ។ ហេតុដូច្នេះ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងរិះរកគ្រប់វិធីសាស្ត្រដើម្បីដោះស្រាយរាល់បញ្ហាទាំងឡាយដែលកើតឡើង កុំឲ្យមានការរំលោភសិទ្ធិទៅលើប្រជាពលរដ្ឋដោយខុសច្បាប់។ បញ្ហាប្រឈមជាច្រើននេះហើយ ទើបបានជារដ្ឋសភានីតិកាលទី៤ បានសម្រេចអនុម័តច្បាប់ស្តីពីអស្សាមិករណ៍ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ និងចូលជាធរមាននៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ មាន៨ជំពូក និង៣៩មាត្រា ដើម្បីកំណត់អំពីការដកហូតសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា ដោយមានការកំណត់យ៉ាងច្បាស់លាស់ពីគោលការណ៍ យន្តការ នីតិវិធីនៃការធ្វើអស្សាមិករណ៍ និងការទូទាត់សំណងដែលសមរម្យ និងយុត្តិធម៌សម្រាប់គម្រោងនីមួយៗ។ ក្រោយពីព្រះរាជាណាចក្រកម្ពុជាបានអនុម័តច្បាប់ស្តីពីអស្សាមិករណ៍រួចមក ចំពោះការដកហូតសិទ្ធិកម្មសិទ្ធិដែលធ្វើឡើងដោយរាជរដ្ឋាភិបាល គឺស្របទៅច្បាប់ដោយក្នុងឆន្ទៈអភិវឌ្ឍជាតិ ហើយប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់នេះ និងយល់ដឹងអំពីនីតិវិធីនៃការទាមទារផងដែរ។ យ៉ាងណាមិញ ទោះបីជាច្បាប់ស្តីពីអស្សាមិករណ៍ បានជួយបង្ការ និងទប់ស្កាត់បញ្ហាប្រឈមរវាងរាជរដ្ឋាភិបាល និងទ្រព្យសម្បត្តិសាធារណៈ ឬ រវាងរាជរដ្ឋាភិបាល និងទ្រព្យសម្បត្តិឯកជនបានពិតមែន ប៉ុន្តែ ឆ្លងតាមរយៈការធ្វើអស្សាមិករណ៍នេះ បានបង្កឲ្យមានប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិកាន់កាប់ស្របច្បាប់ ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ បាត់បង់នូវអត្តសញ្ញាណភូមិសាស្ត្រ និងបញ្ហាជាច្រើនទៀតដែលតែងតែកើតឡើងក្នុងពេលប្រកាសគម្រោង និងក្នុងពេលអនុវត្តគម្រោង។

ដោយសារអស្សាមិករណ៍មានភាពសំខាន់ សម្រាប់ការអភិវឌ្ឍប្រទេសជាតិបែបនេះហើយ ជាហេតុផលដែលនាំឲ្យក្រុមរបស់ខ្ញុំមានការចាប់អារម្មណ៍ខ្លាំង និងចង់ស្វែងយល់ឲ្យកាន់តែច្បាស់អំពីអស្សាមិករណ៍នេះ ទើបបានជាក្រុមរបស់ខ្ញុំសម្រេចចិត្តធ្វើការជ្រើសរើសយកប្រធានបទស្តីពី "**ការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា**" ដើម្បីធ្វើការសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ។

ប្រធានបទនៃសារណាមួយនេះ គឺផ្តោតសំខាន់ទៅលើដំណើរការនៃអស្សាមិករណ៍ និង បញ្ហាប្រឈមដែលកើតមានដោយសារការអនុវត្តជាក់ស្តែងក្នុងការធ្វើអស្សាមិករណ៍។ ពាក់ព័ន្ធប្រធានបទនេះ មានសំនួរគតិយុត្តថាមួយចំនួនបានចោទឡើងថា តើការអនុវត្តចំពោះការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈដូចម្តេច ហើយបញ្ហាប្រឈមអ្វីខ្លះដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយ និងដោះស្រាយដោយវិធីណា?

ដើម្បីធ្វើការបកស្រាយសំនួរគតិយុត្តខាងលើនេះ ក៏ដូចជាប្រធានបទទាំងមូល ក្រុមរបស់ខ្ញុំនឹងធ្វើការបែងចែងជា ពីរជំពូកគឺ **បុព្វហេតុនៃការធ្វើអស្សាមិករណ៍ (ជំពូកទី១)** និង**វិវាទក្នុងអស្សាមិករណ៍ (ជំពូកទី២)**។

# ជំពូកទី១

# ជំពូកទី១

# បុព្វហេតុនៃអស្សាមិករណ៍

*អស្សាមិករណ៍* សម្តៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុ របស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ។ កត្តាជាចម្បង នៃច្បាប់ស្តីពីអស្សាមិករណ៍ គឺការកំណត់គោលដៅ និងគោលបំណង ដើម្បីឲ្យការអនុវត្តឲ្យមានប្រសិទ្ធិភាព និងអានុភាព។ ចំពោះគោលដៅនៃច្បាប់ស្តីពីអស្សាមិករណ៍វិញ បានកំណត់អំពីគោលការណ៍ យន្តការនីតិវិធីនៃអស្សាមិករណ៍ និងសំណងសមរម្យ និងយុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដើម្បីបម្រើផលប្រយោជន៍ជាតិ ផលប្រយោជន៍សាធារណៈ និងការអភិវឌ្ឍក្នុងដែនដីអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។ ការបម្រើផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈ ក៏មានឥទ្ធិពលក្នុងគោលបំណងនៃច្បាប់ស្តីពីអស្សាមិករណ៍នេះផងដែរ គឺធានាការដកហូតសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជន ធានាដល់ការសងសំណងជាមុនដោយសមរម្យ និងយុត្តិធម៌ និងមានវិសាលភាពអនុវត្តទៅលើរាល់គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែ ច្បាប់នេះមិនបានគ្របដណ្តប់ទៅលើកិច្ចព្រមព្រៀងណាមួយ ឬ អនុស្សារណៈស្តីពីការគាំពារវិនិយោគ រវាងរដ្ឋាភិបាល និងប្រទេសជាដៃគូដែលមានចែងពីអស្សាមិករណ៍ទេ លើកលែងតែ មិនមានការព្រមព្រៀងនោះទេ ឬ ក្នុងករណីដែលមានកិច្ចព្រមព្រៀង ឬ អនុស្សារណៈពុំមានចែងពីអស្សាមិករណ៍ស្ថិតក្រោមច្បាប់។

ស្របតាមគោលដៅ និងគោលបំណងដែលបានកំណត់នៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍នេះឆ្នាំ២០១០ ការធ្វើអស្សាមិករណ៍ គឺការអនុវត្តដែលត្រូវប្រព្រឹត្តឡើងតាមតម្រូវការជាតិ និងតាមការកំណត់របស់រាជរដ្ឋាភិបាល ស្ថិតនៅក្រោម គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដូចជា ការអភិវឌ្ឍផ្លូវ អាគារ និងការការពារធនធានធម្មជាតិ។ ក្នុងនោះមានការសាងសង់ ឬ ពង្រីកផ្លូវអយស្ម័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ស្ថានីយ៍ថាមពល និងខ្សែសម្រាប់ការបញ្ជូន ផ្លូវឆ្លាក្រុង ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ទីលានសាធារណៈ ប្រព័ន្ធធារាសាស្ត្រ ទីផ្សារ សួនច្បារ ចំណតយានយន្ត ប្រព័ន្ធលូទឹកកខ្វក់។ ចំពោះការសាងសង់ ឬ ពង្រីកអាគារ គឺសម្រាប់ប្រៃសណីយ៍ ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មាន សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខ និងកីឡាដ្ឋាន សម្រាប់សម្តែងជូនជាសាធារណៈ អាគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីបញ្ហាប្រធានសក្តិដូចជា គ្រោះរញ្ជួយផែនដី ទឹកជំនន់ អគ្គីភ័យ និងគ្រោះ

បាក់ដីជាដើម និងការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ ដើម្បីការពារប្រជាជន និងចាំបាច់ដល់កិច្ចការពារជាតិ ឬ កិច្ចការពារប្រជាជន។ លើសពីនេះ ការការពារធនធានធម្មជាតិ គឺតម្រូវឲ្យរាជរដ្ឋាភិបាលធ្វើការពង្រីកកន្លែងចម្រាញ់ និងកន្លែងប្រព្រឹត្តកម្ម សំណង់ឧបករណ៍ សម្រាប់ការពារធម្មជាតិ និងបរិស្ថាន ពង្រីកអគារ និងឧបករណ៍សម្រាប់ស្រាវជ្រាវ និងសម្រាប់ការធ្វើអាជីវកម្មរ៉ែ និងធនធានធម្មជាតិផ្សេងទៀត ពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្របូមប្រេង និងបណ្តាញដទៃទៀត។

តើអស្សាមិករណ៍នៃព្រះរាជាណាចក្រកម្ពុជាមានសញ្ញាណដូចម្តេច? តើដំណើរការនៃការធ្វើអស្សាមិករណ៍ត្រូវបានបែងចែកជាប៉ុន្មានដំណាក់កាល? តើការធ្វើអស្សាមិករណ៍មានការប្រព្រឹត្តទៅដោយដូចម្តេចខ្លះ? ដូចនេះ នៅក្នុងជំពូកទី១ នឹងធ្វើការបកស្រាយទៅលើ ពីរផ្នែកគឺ **សញ្ញាណទូទៅ** (១.១) និង **នីតិវិធីនៃការអនុវត្តគម្រោងអស្សាមិករណ៍** (១.២)។

## ១.១. សញ្ញាណទូទៅ

ជាទូទៅ ការកសាង គឺជាការរួមចំណែកមួយនៃការអភិវឌ្ឍប្រទេសជាតិ ដើម្បីឲ្យឈានទៅរកភាពរីកចម្រើន ដូចជាការកសាងស្ពាន ថ្នល់ សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដទៃទៀត អ្វីទាំងអស់នេះសុទ្ធសឹងតែជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងប្រទេសជាតិ។ រាជរដ្ឋាភិបាលបាននឹងកំពុងខិតខំរះរកវិធីសាស្ត្រ ដើម្បីឲ្យមានការរីកចម្រើនលើគ្រប់វិស័យ មិនថាជាវិស័យអប់រំ ឬ វិស័យសុខាភិបាល ឬ វិស័យកីឡា ឬ វិស័យទូរគមនាគមន៍ឡើយ។ ការកសាងជាចាំបាច់ត្រូវទាមទារឲ្យមានដីធ្លី ជាកត្តាទីតាំងភូមិសាស្ត្រច្បាស់លាស់សម្រាប់ការអភិវឌ្ឍប្រទេស ហេតុដូច្នេះ ទើបធ្វើឲ្យកើតមាននូវការដកហូតនូវសិទ្ធិកម្មសិទ្ធិស្របច្បាប់លើអចលនវត្ថុពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ។ ការដកហូតអចលនវត្ថុដែលកើតមានឡើងតាមរយៈការធ្វើអស្សាមិករណ៍ រួមមានការដកហូតដី សំណង់អាគារ និងដំណាំដាំដុះក្នុងតំបន់គម្រោង ដើម្បីរៀបចំស្ថាបនា ស្ពារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើដល់ផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និងយុត្តិធម៌ទៅកាន់ជនរងផលប៉ះពាល់ពីគម្រោង។ យ៉ាងណាមិញ ការធ្វើអស្សាមិករណ៍ត្រូវកំណត់ឲ្យបានជាក់លាក់ អំពីប្រភេទអចលនវត្ថុដែលត្រូវយកមកធ្វើអស្សាមិករណ៍ ដោយគិតអំពីទំហំនៃចំណែកដែលត្រូវធ្វើ និងចំណែកដែលនៅសល់មុន និងក្រោយការធ្វើអស្សាមិករណ៍ អ្នកដែលមានសិទ្ធិពាក់ព័ន្ធនឹងចំណែក

នៅសល់នោះ[៣] ប៉ុន្តែ ក្នុងករណីការធ្វើអស្សាមិករណ៍ពិសេស គឺការដកហូតត្រូវបានធ្វើភ្លាម និងជាបន្ទាន់ ដើម្បីការពារសុវត្ថិភាពជូនសាធារណៈជន។

មុនពេលធ្វើអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវរៀបចំគណៈកម្មាធិការ ក្នុងគោលបំណងរៀបចំ និងត្រួតពិនិត្យទៅលើដំណាក់កាលនីមួយៗនៃដំណើរការអស្សាមិករណ៍។ ដូចនេះ បានបង្កើតទៅជាសំណួរថា តើនរណាមានសិទ្ធិធ្វើអស្សាមិករណ៍? តើការធ្វើអស្សាមិករណ៍តម្រូវឲ្យឡើងជាបន្ទាន់ ដោយពុំចាំបាច់ធ្វើតាមដំណាក់កាលដែលច្បាប់បានកំណត់អាចប្រព្រឹត្តឡើងចំពោះករណីណាខ្លះ? ហេតុអ្វីបានជារាជរដ្ឋាភិបាលបង្កើតនូវគណៈកម្មាធិការអស្សាមិករណ៍? តើស្ថាប័នណាមួយជាគណៈកម្មាធិការដឹកនាំក្នុងការធ្វើអស្សាមិករណ៍? តើគណៈកម្មាធិការមានតួនាទី និងភារកិច្ចអ្វីខ្លះ? ដើម្បីឆ្លើយតបនឹងសំនួរគតិយុត្តទាំងបួនខាងលើផ្នែកនេះ នឹងត្រូវធ្វើការបែងចែងជា បីចំណុច គឺ **គោលការណ៍នៃការធ្វើអស្សាមិករណ៍ (១.១.១) អស្សាមិករណ៍ពិសេស (១.១.២)** និង **យន្តការនៃការធ្វើអស្សាមិករណ៍ (១.១.៣)**។

### ១.១.១. គោលការណ៍នៃការធ្វើអស្សាមិករណ៍

អ្នកដែលអាចធ្វើអស្សាមិករណ៍ក្នុងព្រះរាជាណាចក្រកម្ពុជាបាន គឺមានតែរដ្ឋមួយគត់ ដើម្បីបម្រើដល់ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ មិនមានន័យថា រដ្ឋមានសិទ្ធិដកហូតអចលនវត្ថុទាំងអស់នៅក្នុងតំបន់ ដោយពុំមានមូលហេតុច្បាស់លាស់ ឬ យកសិទ្ធិអំណាចជាអាជ្ញាធរមកគាបសង្កត់លើប្រជាពលរដ្ឋបាននោះទេ គឺរាជរដ្ឋាភិបាលចាំបាច់ត្រូវតែបង្កើតគម្រោងអភិវឌ្ឍ សាងសង់ កំណែទម្រង់ និងគម្រោងថវិកាឲ្យបានច្បាស់លាស់ ដោយសំណងត្រូវមានភាពសមរម្យ និងយុត្តិធម៌ ដែលគម្រោងនៅក្នុងអស្សាមិករណ៍ត្រូវបានយកមកប្រើប្រាស់រួមមាន ការអភិវឌ្ឍផ្លូវ អាគារ និងការការពារធនធានធម្មជាតិ ដូចបានរៀបរាប់ក្នុងជំពូកទី១។ បន្ទាប់ពីការរៀបចំគម្រោងបានចប់សព្វគ្រប់ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬ ពុំអាចសង់លំនៅដ្ឋានបាន ឬ ពុំអាចប្រកបអាជីវកម្មផ្សេងទៀតបាន នោះរដ្ឋដាច់ខាតត្រូវតែទទួលទិញនូវអចលនវត្ថុដោយតម្លៃសមរម្យ និងយុត្តិធម៌ស្របទៅតាមសំណើដែលបានស្នើសុំ[៤] ល្គឹកណាប្រជាពលរដ្ឋដែលជាម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិនោះ មិនបានធ្វើការផ្តល់

[៣] មាត្រា៩ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[៤] មាត្រា៨ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

ព័ត៌មានជូនទៅគណៈកម្មាធិការអស្សាមិករណ៍ទេនោះ ការទទួលទិញអចលនវត្ថុទាំងឡាយបន្ថែមលើសពីគម្រោងដែលបានគ្រោងទុកនោះ ក៏ពុំអាចកើតមានដែរ។ ចំពោះអចលនវត្ថុដែលនៅសល់ពីការប្រើប្រាស់ក្នុងការធ្វើអស្សាមិករណ៍ រដ្ឋត្រូវផ្តល់អាទិភាពលក់ជូនម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិតាមអត្រាតម្លៃនៃការទូទាត់សំណង ដែលបានធ្វើឡើងមុនពេលធ្វើអស្សាមិករណ៍ ប៉ុន្តែ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនព្រមទទួលទិញយកអចលនវត្ថុដែលនៅសល់វិញទេ អចលនវត្ថុនោះត្រូវបានរក្សាទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ[៥] គឺគណៈកម្មាធិការមិនអាចធ្វើការលក់ជូនម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិដើមវិញ នៅក្នុងតម្លៃទីផ្សារបច្ចុប្បន្នក្រោយពីមានការស្ថាបនាបាននោះទេ ព្រោះថាទីណាមានការអភិវឌ្ឍច្រើន តម្លៃអចលនវត្ថុនៅទីនោះនឹងមានតម្លៃតែងកើនឡើងជានិច្ច ជាហេតុធ្វើឲ្យខាតបង់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ចំពោះអចលនវត្ថុទាំងឡាយណាដែលដកហូតពីម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិក្នុងតំបន់គម្រោងអស្សាមិករណ៍ ត្រូវប្រើប្រាស់ សម្រាប់តែក្នុងគោលដៅដូចដែលបានគ្រោង ចំពោះការធ្វើអស្សាមិករណ៍តែប៉ុណ្ណោះ ដោយអចលនវត្ថុទាំងនោះមិនអាចទុកនៅចោលឲ្យនៅទំនេរដោយគ្មានហេតុផលសមស្រប ឬ ផ្ទេរឲ្យទៅតតិយជនណាម្នាក់ ក្នុងគោលដៅណាមួយបម្រើផលប្រយោជន៍ឯកជនបានឡើយ គឺរាល់ការដកហូតអចលនវត្ថុតាមរយៈរូបភាពអស្សាមិករណ៍នេះ ជាទូទៅ គឺសម្រាប់តែបម្រើផលប្រយោជន៍សាធារណៈ និងប្រទេសជាតិតែប៉ុណ្ណោះ ដោយមិនសម្តៅចំពោះផលប្រយោជន៍ឯកជនឡើយ។ យ៉ាងណាមិញអស្សាមិករណ៍ ក៏អាចធ្វើទៅលើអចលនវត្ថុមួយផ្នែក ឬ ទាំងស្រុង ឬ លើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ។ តើអ្វី គឺជាការធ្វើអស្សាមិករណ៍លើអចលនវត្ថុមួយផ្នែក ឬ ទាំងស្រុង ឬ សិទ្ធិប្រត្យក្សនៃអចលនវត្ថុ? តើវាមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ?

តបតាមសំណួរខាងលើ ការធ្វើអស្សាមិករណ៍មួយផ្នែក គឺសម្តៅទៅលើការដកហូតផ្នែកណាមួយនៃអចលនវត្ថុពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដើម្បីយកមកប្រើប្រាស់នៅក្នុងគម្រោងអស្សាមិករណ៍។ ជាក់ស្តែង នៅផ្សារកំពង់ជ្រៃ ស្រុកកោះអណ្តែត ខេត្តតាកែវ រដ្ឋាភិបាលបានធ្វើអស្សាមិករណ៍ទៅលើដីរបស់មីងសនដែលជាអាជីវករលក់ដូរម្នាក់ ដោយដកហូតផ្នែកខាងមុខ និងចំហៀងខាងស្តាំ ដើម្បីយកមកពង្រីកធ្វើជាផ្លូវថ្នល់បម្រើផលប្រយោជន៍សាធារណៈ ដូចមានរូបនៅក្នុងឧសម្ព័ន្ធទី៦។ ចំណែកឯ ការធ្វើអស្សាមិករណ៍ទាំងស្រុង គឺសម្តៅដល់ការដកហូតនូវសិទ្ធិលើអចលនវត្ថុទាំងស្រុងពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដើម្បីយកមកប្រើប្រាស់ក្នុងគម្រោងអស្សាមិករណ៍។ ក្នុងនោះ ករណីគម្រោងសាងសង់ស្ពានខាងជើងនៃស្ពានព្រែកក្តាម ស្ថិតក្នុងខេត្ត

[៥] វាក្យខណ្ឌទី២ មាត្រា៩ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

កណ្តាល បង្កឲ្យមានការធ្វើអស្សាមិករណ៍ទាំងស្រុងទៅលើផ្ទះរបស់អ្នកស្រី សូ ផល្លីយ៉ា ដែលជាអ្នកភូមិរស់នៅក្នុង ភូមិទួលងោក ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល ដែលបានអនុវត្តដីការុះរើនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥[៦] ដូចមានរូបនៅក្នុងឧសម្ព័ន្ធទី៧។ ចំពោះពាក្យថា "សិទ្ធិប្រត្យក្ស" គឺជាសិទ្ធិគ្រប់គ្រងដោយចំពោះលើវត្ថុ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន[៧]។ អ្នកទទួលបានសិទ្ធិប្រត្យក្ស គឺទទួលបានត្រឹមសិទ្ធិប្រើប្រាស់ និងអាស្រ័យផលទៅលើអចលនវត្ថុតែប៉ុណ្ណោះ[៨]។ ជាក់ស្តែង គម្រោងពង្រីកផ្លូវ និងសាងសង់ស្ពានអាកាសដែលធ្វើនៅសង្កាត់ចោមចៅ ស្របតាមបណ្តោយប្រលានយន្តហោះអន្តរជាតិភ្នំពេញ ដែលមានប្រវែង១៨ម៉ែត្រ គិតត្រឹមគំនូសពណ៌លឿងនៃទ្រូងផ្លូវ គឺគម្រោងនោះបានប៉ះចំស្លានីយ៍ប្រេងឥន្ធនៈមួយកន្លែង ដែលម្ចាស់សិទ្ធិទទួលបានសិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យផលពីរដ្ឋ តាំងពីឆ្នាំ១៩៩១[៩] ដូចមានរូបនៅក្នុងឧសម្ព័ន្ធទី៨។

### ១.១.២. អស្សាមិករណ៍ពិសេស

ការធ្វើអស្សាមិករណ៍ មិនមែនសុទ្ធតែត្រូវធ្វើទៅតាមការកំណត់នៃច្បាប់ ដោយត្រូវឆ្លងការពិភាក្សាជាមួយម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិជាមុននោះទេ ប៉ុន្តែ ចំណុចដែលសំខាន់នៃការធ្វើអស្សាមិករណ៍ត្រូវធ្វើឡើងដើម្បីផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈ។ ចំពោះពេលមានហេតុការណ៍បន្ទាន់ ដែលតម្រូវឲ្យរដ្ឋធ្វើការដកហូតអចលនវត្ថុពីប្រជាពលរដ្ឋនោះ ការធ្វើអស្សាមិករណ៍ពុំចាំបាច់ត្រូវមានការគ្រោងទុកដោយល្អិតល្អន់ច្បាស់លាស់ ឬ មានគណៈកម្មាធិការត្រឹមត្រូវ ឬ ត្រូវមានការយល់ព្រមពីម្ចាស់អចលនវត្ថុនោះឡើយ។

ក្នុងករណីពិសេសនានានៃការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចាំបាច់ដើម្បីផលប្រយោជន៍សាធារណៈ រាជរដ្ឋាភិបាលពុំចាំបាច់ធ្វើការពិគ្រោះយោបល់ពីម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិឡើយ ឬ បុគ្គលទទួលបានផលប្រយោជន៍ណាមួយឡើយ ដោយការអនុម័តចំពោះការធ្វើអស្សាមិករណ៍ ត្រូវស្ថិតនៅក្រោមអំណាចឆន្ទានុសិទ្ធិរបស់រាជរដ្ឋាភិបាលផ្ទាល់តែម្តង។ ប៉ុន្តែ មិនមានន័យថា រដ្ឋអាចធ្វើការដកហូតដោយពុំមានមូលហេតុច្បាស់លាស់នោះទេ ដោយនៅពេលខ្លះ

---

[៦] កាសែតកម្ពុជាថ្មី ដោយៈ វុំបូរ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥

[៧] មាត្រា១៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[៨] មាត្រា១៣២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[៩] https://www.facebook.com/MeasRithyHangMeas/videos/1470063116351128/ ចូលមើលថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៧

ការធ្វើអស្សាមិករណ៍ត្រូវធ្វើជាបន្ទាន់ ដើម្បីការពារសុវត្ថិភាព និងសុខមាលភាពជូនសាធារណៈជន ដូចជា ការបញ្ចៀសពីករណីប្រធានសក្តិ (ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត រញ្ជួយដី...) សង្គ្រាមដែលបម្រុងនឹងកើតឡើង និងស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលអាចនឹងធ្វើការដកហូតអចលនវត្ថុដោយផ្នែក ឬ ទាំងស្រុង ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ឡើយ។ បន្ទាប់ពីហេតុការណ៍អាសន្ននៃការការពារសុវត្ថិភាពសាធារណៈទាំងនោះត្រូវបានបញ្ចប់ រាជរដ្ឋាភិបាលត្រូវប្រគល់អចលវត្ថុដែលបានដកហូតទាំងឡាយនោះ ជូនទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដើមវិញ ដោយពុំមានការសងជាសំណង ឬ ទាមទារសំណងសមរម្យណាមួយជាថ្នូរចំពោះការដកហូតអចលនវត្ថុ ស្ថិតក្រោមរូបភាពអស្សាមិករណ៍ពិសេសនោះទេ។

ជាក់ស្តែង នៅឆ្នាំ២០១១ មានជម្លោះព្រំដែនរវាងកម្ពុជា និងថៃ អំពីបញ្ហាប្រាសាទព្រះវិហារនៅពេលនោះដែរ ដែលបង្កឲ្យមានការដកទ័ពចេញពីតំបន់គ្មានយោធា ចំងាយ ១៧គីឡូម៉ែត្រពីព្រំដែន[១០]។ ជាហេតុធ្វើឲ្យមានការធ្វើអស្សាមិករណ៍ (ជម្លៀសប្រជាជន) ទៅលើតំបន់ដែលយោធាតាំងនៅ ដើម្បីជៀសវាងការផ្ទុះអាវុធរវាងកងទ័ពកម្ពុជា និងថៃ ដែលអាចបង្កជាសោកនាដកម្មទៅលើប្រជាជននៅតំបន់នោះ។

### ១.១.៣. យន្តការនៃការធ្វើអស្សាមិករណ៍

ជាទូទៅ នៅក្នុងគម្រោងនៃការអភិវឌ្ឍប្រទេសជាតិ សុទ្ធតែត្រូវធ្វើឡើងដោយមានការគ្រោងទុកជាមុនយ៉ាងម៉ត់ចត់ នៅក្នុងគម្រោងនីមួយៗចាំបាច់ត្រូវការមានអ្នកគ្រប់គ្រងត្រួតពិនិត្យ និងដោះស្រាយនៅពេលដែលគម្រោងនោះ មានបញ្ហាដោយប្រការណាមួយនោះ។ ហេតុនេះហើយ ទើបឃើញថាគ្រប់គម្រោងទាំងអស់សុទ្ធតែមានគណៈកម្មាធិការមួយយ៉ាងតិច ដើម្បីទទួលខុសត្រូវលើគម្រោងនោះ។ ងាកមកវិញ បើការធ្វើអស្សាមិករណ៍វិញក៏ដូចគ្នាផងដែរ ក្នុងការធ្វើអស្សាមិករណ៍ដាច់ខាតត្រូវតែមានអ្នកដឹកនាំច្បាស់លាស់ មុនពេលការអនុវត្តអស្សាមិករណ៍ត្រូវបានចាប់ផ្តើម។ អ្នកដឹកនាំ ត្រួតពិនិត្យនៅក្នុងគម្រោង និងសកម្មភាពក្នុងការដកហូតនានា ក្នុងការធ្វើអស្សាមិករណ៍រួមមាន គណៈកម្មាធិការអស្សាមិករណ៍ អនុគណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដើម្បីគ្រប់គ្រង និងស្វែងរកដំណោះស្រាយនានា ចំពោះវិវាទទាក់ទងនឹងអស្សាមិករណ៍ដែលបង្កើតបានឡើងនោះ។ ក្នុងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើរតួយ៉ាង

[១០] https://www.swp-berlin.org/fileadmin/contents/products/projekt_papiere/BCAS2013_Rosita_Dewi.pdf

សំខាន់ក្នុងការទូទាត់សំណងដោយភាពសមរម្យ និងយុត្តិធម៌ដល់ប្រជាពលរដ្ឋជាម្ចាស់សិទ្ធិ និង/ឬ ម្ចាស់អចលនវត្ថុ ដែលទទួលផលប៉ះពាល់ពីគម្រោងអស្សាមិករណ៍។ ដូចនេះ គណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមទាំងតំណាងមកពីក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម។ រីឯ អនុគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និងដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងមានតំណាងមន្ទីរជំនាញអាជ្ញាធរពាក់ព័ន្ធចូលរួម។ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា សម្រាប់បណ្តឹងអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម។

### ១.២. នីតិវិធីនៃការធ្វើអស្សាមិករណ៍

អស្សាមិករណ៍ ជាទូទៅត្រូវបានគេធ្វើឡើងក្នុងបែបបទនៃគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈដូចជា គម្រោងសាងសង់ផ្លូវថ្នល់ ស្ពាន មន្ទីរពេទ្យ សាលារៀន ឬ ព្រលានយន្តហោះ។ ការតាក់តែងប្លង់គម្រោង និងការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គឺជាដំណើរការមួយដ៏វែងឆ្ងាយ និងស្មុគស្មាញ ពាក់ព័ន្ធនឹងភ្នាក់ងារស្ថាប័នផ្សេងៗរបស់រដ្ឋ ហើយតម្រូវឲ្យមានដូចជាអ្នកជំនាញការ អ្នកបច្ចេកទេស និងចំនួនថវិកាយ៉ាងច្រើន អាស្រ័យលើគម្រោងនីមួយៗ។ គម្រោងទាំងឡាយអាចត្រូវការចំណាយពេលវេលាច្រើនឆ្នាំទើបធ្វើចប់ ហើយជួនកាលត្រូវធ្វើជាផ្នែកៗដូចជាការសាងសង់ផ្លូវជាតិម្តងមួយកំណាត់ៗ។ នៅក្នុងវដ្តនៃគម្រោងមួយមាន ការកំណត់អំពីសេចក្តីត្រូវការ ការសិក្សាអំពីលទ្ធភាពមុនដំណាក់កាលតាក់តែងគម្រោង ការសិក្សាអំពីលទ្ធភាពគម្រោង និងការតាក់តែងប្លង់គម្រោងលម្អិត ការអនុវត្តនូវគម្រោង ឬ សមាសភាគនៃគម្រោងដែលទទួលបានការសម្រេចឯកភាព និងសម្រាប់គម្រោង ការតាមដាន និងការវាយតម្លៃលើការអនុវត្តគម្រោង។ ពាក់ព័ន្ធនឹងបរិស្ថាន ម្ចាស់គម្រោងអស្សាមិករណ៍ ត្រូវដាក់ពាក្យស្នើសុំពិនិត្យ និងធ្វើរបាយការណ៍វាយតម្លៃផលប៉ះពាល់ដល់បរិស្ថានមុនពេលធ្វើអស្សាមិករណ៍ ដើម្បីធានាបានថាគម្រោងនេះពិតជាអាចអនុវត្តបាន ដោយមិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានឡើយ[១១]។ ដំណើរការជាក់ស្តែងនៃការធ្វើអស្សាមិករណ៍ដែលពាក់ព័ន្ធនឹងសកម្មភាពជាច្រើននៅក្នុងជំហានមួយចំនួន ព្រមគ្នាជាមួយនិងការរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនោះ។ ជាក់ស្តែង នីតិវិធីនៃការធ្វើអស្សាមិករណ៍ គឺមានកំណត់យ៉ាងច្បាស់ នៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍នៃព្រះរាជាណាចក្រកម្ពុជា ដោយនីតិវិធី

[១១] មាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឆ្នាំ១៩៩៩

នេះបានចូលរួមដល់ការប្រព្រឹត្តទៅនៃអស្សាមិករណ៍ឲ្យទទួលបានជោគជ័យ ទៅតាមការគ្រោងទុករបស់រដ្ឋ។ នីតិវិធីនៃការធ្វើអស្សាមិករណ៍ ត្រូវបានបែងចែកជា **បីដំណាក់កាល**ដូចជា **នីតិវិធីមុនធ្វើអស្សាមិករណ៍** (១.២.១) បន្ទាប់មកបន្តដល់ **នីតិវិធីក្នុងពេលធ្វើអស្សាមិករណ៍** (១.២.២) និងឈានចូល **ការទូទាត់សំណងនៃអស្សាមិករណ៍** (១.២.៣) ដោយដំណាក់កាលទាំងនេះរដ្ឋត្រូវតែយកមកអនុវត្តនៅក្នុងនីតិវិធីនៃការធ្វើអស្សាមិករណ៍។

### ១.២.១. នីតិវិធីមុនធ្វើអស្សាមិករណ៍

ជាទូទៅ មុនពេលធ្វើអស្សាមិករណ៍ រដ្ឋ ឬ ក្រសួងស្ថាប័នរដ្ឋដែលទទួលខុសត្រូវនៅក្នុងការអនុវត្តគម្រោង និងធ្វើការរៀបចំតាក់តែងប្លង់គម្រោង ព្រមទាំងធ្វើការកំណត់អំពីសេចក្តីត្រូវការនៃការធ្វើអស្សាមិករណ៍សម្រាប់គម្រោងនោះ។ រដ្ឋ ឬ ក្រសួងស្ថាប័នរដ្ឋត្រូវធ្វើការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ដែលក្នុងនោះ ត្រូវបូករួមបញ្ចូលនូវចំនួនថវិកាប៉ាន់ប្រមាណសម្រាប់សងសំណងផងដែរ។ សំណងនេះត្រៀមទុកសងក្រុមបុគ្គលដែលមានសិទ្ធិទទួលបានសំណងរួមមាន៖ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលសំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ រួមមាន កម្មសិទ្ធិករ ភោគី និងអ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដី ដែលជាអ្នកទទួលរងផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍[១២]។ ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចជាក្រសួងស្ថាប័នក្នុងការធ្វើអស្សាមិករណ៍វិញ បន្ទាប់ពីមានការអនុម័តនូវកញ្ចប់ថវិកាគម្រោង ក្រសួងស្ថាប័ននោះ ត្រូវដាក់សំណើសុំការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលសម្រាប់គម្រោងនោះ។

#### ក. គម្រោង

ដើម្បីធ្វើសកម្មភាពអស្សាមិករណ៍ណាមួយប្រកបដោយចីរភាព ដាច់ខាតត្រូវតែមានការរៀបចំគម្រោងឲ្យលម្អិត ដោយផ្អែកទៅលើគោលការណ៍នៃផលប្រយោជន៍ជាតិ និងផលប្រយោជន៍សាធារណៈ ទើបអាចដាក់សំណើជូនទៅរាជរដ្ឋាភិបាល ដើម្បីធ្វើការត្រួតពិនិត្យ និងសម្រេចបាន។ គណៈកម្មាធិការអស្សាមិករណ៍ ធ្វើការរៀបចំនូវសំណើស្តីពីគម្រោងអស្សាមិករណ៍ ដោយចាប់ផ្តើមពីការធ្វើការអង្កេត ដើម្បីកត់ត្រាជាលម្អិតនូវភិនភាគនៃអចលនវត្ថុពាក់ព័ន្ធ និងអំពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិនានាលើអចលនវត្ថុនោះ។ សម្រាប់ករណីភាគច្រើនដែលបានកើតមាន ការធ្វើអង្កេតនោះត្រូវរួមបញ្ចូលនូវការពិគ្រោះយោបល់ជាសាធារណៈជាមួយ អាជ្ញាធររាជធានីខេត្ត ក្រុង

[១២] មាត្រា៩ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

ស្រុក ខណ្ឌ និងឃុំ សង្កាត់ ព្រមទាំងតំណាងប្រជាពលរដ្ឋក្នុងភូមិឃុំដែលជាទីតាំងរងអស្សាមិករណ៍ ដើម្បីផ្តល់ នូវព័ត៌មានច្បាស់លាស់ជាក់លាក់ និងប្រមូលមតិយោបល់របស់រាល់ភាគីដែលពាក់ព័ន្ធនឹងសំណើគម្រោងនោះ[១៣]។ ជាក់ស្តែង កាសែតខេមបូឌាដេលី ចុះនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ បានបង្ហាញថា គម្រោងស្ថាបនាផ្លូវបេតុងមួយខ្សែប្រវែង ៥គីឡូម៉ែត្រ និងត្រូវប្រើរយៈពេល ៥ឆ្នាំ ដែលសាលារាជធានីភ្នំពេញបានបង្កើតនៅលើកំណាត់ផ្លូវដែកមួយ ដែលលាតសន្ធឹងពីផ្លូវជាតិលេខ៥ កាត់តាមសង្កាត់មួយចំនួន នៅក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នឹងធ្វើឲ្យប៉ះពាល់ដល់ដីធ្លី និងផ្ទះសម្បែងរបស់ប្រជាពលរដ្ឋ ដែលបានសង់ជាជួរនៅអមសងខាងផ្លូវដែកនោះ[១៤] ដូចមានរូបនៅក្នុងឧបសម្ព័ន្ធទី១០។ ក្នុងករណីមួយទៀត ដែលទទួលបានពីកាសែតខេមបូឌាដេលីដដែល ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ បានសរសេរទាក់ទងនឹងគម្រោងរបស់សាលារាជធានីភ្នំពេញដែលតំណាងដោយលោក ប៉ា សុជាតិវង្ស ជាអភិបាលក្រុងភ្នំពេញ មានគម្រោងសាងសង់ផ្លូវមួយខ្សែកាត់ដែលមានចម្ងាយ ៥០ម៉ែត្រពីកាំជណ្តើរនៃព្រះវិហារអាល់សឺកាល (ព្រះវិហារអ៊ីស្លាម) មានទីតាំងនៅក្បែរតំបន់បឹងកក់ ត្រូវប្រើប្រាស់ថវិកាចំនួន ២,៨លានដុល្លារ ដោយនៅក្នុងគម្រោងនឹងបង្កើតឲ្យមាននូវការសាងសង់ខនដូរ និងទីលានវាយកូនង្គោលក្នុងពេលអនាគត ដូចរូបនៅក្នុងឧបសម្ព័ន្ធទី១០[១៥]។

បន្ទាប់ពីបានបញ្ចប់នូវរាល់សកម្មភាព និងការធ្វើកំណត់ត្រាទាំងឡាយដែលច្បាប់តម្រូវឲ្យធ្វើរួចមក សំណើគម្រោងអស្សាមិករណ៍ និងរបាយការណ៍លម្អិតស្តីពីការអង្កេត រួចរាល់ហើយនោះ អនុសាសន៍របស់គណៈកម្មាធិការអស្សាមិករណ៍ នឹងត្រូវដាក់ជូនទៅរាជរដ្ឋាភិបាល ដើម្បីធ្វើការត្រួតពិនិត្យ និងសម្រេច។ មុននឹងធ្វើសម្រេចអំពីសំណើគម្រោងអស្សាមិករណ៍ ច្បាប់នេះគឺតម្រូវឲ្យរាជរដ្ឋាភិបាលធ្វើការពិភាក្សាពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងតំបន់គម្រោងអស្សាមិករណ៍ ដើម្បីប្រមូលមតិយោបល់របស់ភូមិ ឬ សហគមន៍ពាក់ព័ន្ធ យោបល់របស់អាជ្ញាធរដែនដីមូលដ្ឋាន និងរបស់ភាគីពាក់ព័ន្ធនៅក្នុងគម្រោងនោះ។ លើសពីនេះក៏ត្រូវធ្វើការអង្កេត ដើម្បីប្រមូលព័ត៌មានលម្អិតអំពីម្ចាស់កម្មសិទ្ធិ និងម្ចាស់សិទ្ធិនានាលើក្បាលដី និងទ្រព្យដែលបម្រុងនឹងរងផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍នោះ។

---

[១៣] វាក្យខណ្ឌទី២ មាត្រា១៦ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[១៤] http://www.cambodiadailykhmer.com/35832 ចូលមើលថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៧

[១៥] http://www.cambodiadailykhmer.com/35919 ចូលមើលថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៧

### ខ. ការប្រកាសគម្រោង

បន្ទាប់ពី រាជរដ្ឋាភិបាលបានពិនិត្យ និងសម្រេចឯកភាពលើសំណើគម្រោងអស្សាមិករណ៍រួចមក គណៈកម្មាធិការអស្សាមិករណ៍ នឹងចេញសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍។ សេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ នឹងកំណត់យ៉ាងច្បាស់លាស់អំពីគោលបំណងនៃគម្រោង និងព័ត៌មានពាក់ព័ន្ធលម្អិត ដើម្បីឲ្យជនរងផលប៉ះពាល់ដោយសារគម្រោងនោះ អាចដឹងអំពីទីតាំងគម្រោង អំឡុងពេលសម្រាប់ការអនុវត្តគម្រោង និងអាជ្ញាធរមានសមត្ថកិច្ចក្នុងការអនុវត្តនូវការធ្វើអស្សាមិករណ៍។ ដោយគណៈកម្មាធិការអស្សាមិករណ៍នឹងផ្ដល់ច្បាប់ចម្លងនៃសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ ព្រមទាំងច្បាប់ចម្លងនៃច្បាប់ស្ដីពីអស្សាមិករណ៍ ដល់រាល់ជនរងប៉ះពាល់ដោយសារគម្រោង។

គណៈកម្មាធិការអស្សាមិករណ៍ ដាក់ស្លាកសម្គាល់នៅលើទីតាំងគម្រោង ដែលបង្ហាញឲ្យឃើញអំពីអចលនវត្ថុដែលត្រូវធ្វើអស្សាមិករណ៍ និងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍នោះ និងធ្វើការបិទផ្សព្វផ្សាយនៅសាលាឃុំនៃទីតាំងគម្រោង។

ការផ្សព្វផ្សាយសេចក្ដីជូនដំណឹងនេះមានភាពចាំបាច់ណាស់ ពីព្រោះបន្ទាប់ពីមានការចេញសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍រួចមក ច្បាប់មិនអនុញ្ញាតឲ្យធ្វើការលក់ ឬ ផ្ទេរសិទ្ធិលើអចលនវត្ថុពាក់ព័ន្ធ ឬ ធ្វើការសាងសង់សំណង់ថ្មី ឬ សង់បន្ថែមលើសំណង់ដែលមានស្រាប់លើដីនោះឡើយ ដូចមានចែងក្នុងវាក្យខណ្ឌទី១ មាត្រា៣០ នៃច្បាប់ស្ដីពីអស្សាមិករណ៍ ឆ្នាំ២០១០។ រដ្ឋនឹងមិនទទួលស្គាល់នូវការលក់ ឬ ការផ្ទេរសិទ្ធិណាមួយដែលច្បាប់នេះបានហាមឃាត់ឡើយ ហើយនិងមិនផ្ដល់សំណងចំពោះសំណង់ថ្មី ឬ សំណង់ពង្រីកបន្ថែមដែល ច្បាប់នេះបានហាមឃាត់នោះផងដែរ។ រដ្ឋនឹងធ្វើការដោះស្រាយជាមួយម្ចាស់អចលនវត្ថុ និងម្ចាស់សិទ្ធិទាំងឡាយលើអចលនវត្ថុនោះដែលមានសិទ្ធិនោះនៅត្រឹមថ្ងៃចេញសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍តែប៉ុណ្ណោះ។

ជាក់ស្ដែង អាគារប៊ូឌីញ"ស" ជាអាគារមួយដែលបានសាងសង់នៅឆ្នាំ១៩៦៨ ក្នុងសម័យអាណានិគមនិយមបារាំង មានការជូនដំណឹងជាច្រើនដងដើម្បីឲ្យប្រជាពលរដ្ឋដែលកំពុងរស់នៅលើសំណង់អាគារដ៏ចំណាស់មួយនេះធ្វើការផ្លាស់ទីលំនៅ។ លុះដល់ចុង ខែតុលា ឆ្នាំ២០១៦ លោក ជា សុផារ៉ា ជារដ្ឋមន្ត្រីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចេញសេចក្ដីប្រកាស

មួយស្តីពីគម្រោងអភិវឌ្ឍន៍នៅលើទីតាំងអគារប៊ូឌីញ ក្នុងគោលបំណង ដើម្បីឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ រស់នៅដោយសេចក្តីថ្លៃថ្នូរ សុវត្ថិភាព និងសុខុមាលភាព ដូចមានរូបនៅក្នុងឧសម្ព័ន្ធទី១១[១៦]។

### ១.២.២. នីតិវិធីក្នុងពេលធ្វើអស្សាមិករណ៍

បន្ទាប់ពីការរៀបចំគម្រោង និងសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាលរួចមក គឺគណៈកម្មាធិការអស្សាមិករណ៍ នឹងចេញសេចក្តីសម្រេចជាផ្លូវការអំពីការដកហូតទ្រព្យ និងជូនដំណឹងដល់ជនរងផលប៉ះពាល់អំពីសេចក្តីសម្រេចនោះ។ សេចក្តីជូនដំណឹងនេះ នឹងរៀបរាប់អំពីសិទ្ធិលើអចលនវត្ថុដែលនឹងត្រូវបានដកហូត ចំនួនសំណងដែលត្រូវផ្តល់ជូន និងកាលបរិច្ឆេទចុងក្រោយសម្រាប់ការចាកចេញពីទីតាំង ដែលត្រូវធ្វើការដកហូតនោះ។ គណៈកម្មាធិការអស្សាមិករណ៍ នឹងផ្តល់សំណងពេញលេញតាមដែលគណៈកម្មាធិការនេះកំណត់ឃើញថាជាសំណងសមរម្យ និងយុត្តិធម៌ ជូនដល់ម្ចាស់អចលនវត្ថុ និងម្ចាស់សិទ្ធិលើអចលនវត្ថុនោះ។ នៅពេលដែលរដ្ឋសម្រេចធ្វើអស្សាមិករណ៍ទៅលើអចលនវត្ថុ ដើម្បីពង្រីកផ្លូវ ឬ សាងសង់ស្ពានថ្មី ឬ សាលារៀនថ្មី នោះមានមនុស្សជាច្រើនដែលកំពុងរស់នៅ និងកំពុងប្រកបរបររកស៊ីនៅតំបន់នោះ នឹងទទួលបាននូវអត្ថប្រយោជន៍ពីគម្រោងអភិវឌ្ឍថ្មីនោះ។ ប៉ុន្តែ ក៏មានមនុស្សខ្លះទៀតមិនសូវមានសំណាង ជាពិសេស គឺជនដែលមានទ្រព្យត្រូវបានធ្វើអស្សាមិករណ៍ ជនដែលត្រូវផ្លាស់ប្តូរទីតាំងនូវទីលំនៅ ឬ កន្លែងប្រកបរបររកស៊ីទៅកន្លែងថ្មី ឬ ជនដែលបាត់បង់ការងារ និងមធ្យោបាយចិញ្ចឹមជីវិត ដោយសារតែគម្រោងអភិវឌ្ឍនោះ។

ប្រសិនបើ បុគ្គលណាមួយបដិសេធមិនព្រមចាកចេញពីទីតាំង ដែលត្រូវបានធ្វើការដកហូតនោះ នៅពេលផុតកាលកំណត់ដូចដែលបានបញ្ជាក់ក្នុងសេចក្តីជូនដំណឹងនោះទេ គណៈកម្មាធិការអស្សាមិករណ៍ នឹងអាចស្នើសុំការអន្តរាគមន៍ពីអាជ្ញាធរសាធារណៈ ឬ អាជ្ញាធរមានសមត្ថកិច្ច ចំពោះការចាត់វិធានការស្របច្បាប់ ដើម្បីសម្រេចឲ្យបាននូវការធ្វើ លទ្ធកម្មជាក់ស្តែងទៅលើអចលនវត្ថុដែលត្រូវបានដកហូតនោះ រួមទាំងវិធានការបណ្តេញជនទាំងនោះដោយបង្ខំចេញពីទីតាំងដកហូតផងដែរ[១៧]។ ដំណើរការអស្សាមិករណ៍ អាចប្រព្រឹត្តទៅបានដដែល ទោះបីជា បណ្តឹងមិនទាន់បាន

[១៦] កាសែតកោះសន្តិភាព ចុះនៅថ្ងៃសុក្រ ទី២៨ ខែតុលា ឆ្នាំ២០១៦ ម៉ោង ១៤:៣៧ ដោយ: ម៉ម វ៉ាន

[១៧] វាក្យខណ្ឌទី២ មាត្រា៣១ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

ដោះស្រាយរួចរាល់ក៏ដោយ និងចំពោះបុគ្គលទាំងឡាយណាដែលមិនសុខចិត្ត នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងតវ៉ារបស់ខ្លួន ទោះបីជា ក្រោយពេលដែលបុគ្គលទាំងនោះបានទទួលនូវការផ្តល់សំណង ឬ បន្ទាប់ពីមានការដកហូតទ្រព្យជាក់ស្តែងរួចហើយក៏ដោយ។

**ក. ការដកហូតអចលនវត្ថុ**

បន្ទាប់ពី ការទូទាត់សំណងរួចរាល់ និងបានធ្វើការប្រកាសឲ្យដំណើរការសកម្មភាពគម្រោងអស្សាមិករណ៍ពីរាជរដ្ឋាភិបាលហើយនោះ កម្មសិទ្ធិរបស់ប្រជាពលរដ្ឋលើអចលនវត្ថុ នឹងត្រូវបានកាត់ផ្តាច់ទាំងស្រុង។ ប៉ុន្តែ ប្រជាពលរដ្ឋដែលទទួលបានសំណង ដោយសមរម្យ និងយុត្តិធម៌ ហើយនោះ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិទាំងនោះ អាចកាន់កាប់លើអចលនវត្ថុដែលរងផលប៉ះពាល់ពីអស្សាមិករណ៍បានត្រឹមរយៈពេល មួយខែប៉ុណ្ណោះ លើកលែងតែមានការព្រមព្រៀង។ ក្នុងពេលដែលរស់នៅ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ត្រូវតែទទួលខុសត្រូវក្នុងការថែរក្សា ស្នាក់អាស្រ័យ និងទទួលផលដដែលពីអចលនវត្ថុ រហូតដល់មានការទទួលយកអចលនវត្ថុដោយគណៈកម្មាធិការអស្សាមិករណ៍[១៩]។ ពេលដែលគណៈកម្មាធិការទទួលយកអចលនវត្ថុហើយ ម្ចាស់សិទ្ធិ និង/ឬ ម្ចាស់អចលនវត្ថុត្រូវតែរុះរើសំណង់របស់របរចេញពីកន្លែង ដែលត្រូវធ្វើអស្សាមិករណ៍ តាមសេចក្តីជូនដំណឹងរបស់គណៈកម្មាធិការអស្សាមិករណ៍ ចាប់ពីថ្ងៃចេញសេចក្តីប្រកាសគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិពុំអាចលក់ ឬ ផ្ទេរអចលនវត្ថុនោះឲ្យអ្នកដទៃបានទៀតឡើយ មិនតែប៉ុណ្ណោះ លិខិតឯកសារនានា និងនីតិវិធីទាំងអស់ដែលផ្ទុយនឹងច្បាប់ស្តីពីអស្សាមិករណ៍ ត្រូវចាត់ទុកជាមោឃៈ។ ចំពោះការប្រើប្រាស់ដី ឬ អចលនវត្ថុដែលពាក់ព័ន្ធត្រូវរក្សាក្នុងលក្ខណៈដើម និងទំហំប្រើប្រាស់ដូចមាននៅពេលចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ និងមិនត្រូវសាងសង់សំណង់នៅលើដីនោះថែមទៀតឡើយ។

**ខ. ការអនុវត្តគម្រោង**

នៅពេលដែលគណៈកម្មាធិការអស្សាមិករណ៍ បានប្រកាសទទួលយកអចលនវត្ថុពី ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិហើយនោះ រដ្ឋ ឬ ម្ចាស់គម្រោងអស្សាមិករណ៍ត្រូវអនុវត្តទៅលើគម្រោងនោះ។ ការអនុវត្តគម្រោង គឺជាកិច្ចដំណើរការមួយយ៉ាងសំខាន់ដែលរដ្ឋ ឬ ម្ចាស់គម្រោងត្រូវ

[១៩] មាត្រា២៧ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

យកចិត្តទុកដាក់ក្នុងពេលអនុវត្តនោះ។ ដោយសារការធ្វើអស្សាមិករណ៍ជាសកម្មភាពមួយដែលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរស់នៅរបស់ប្រជាពលរដ្ឋ ដូច្នេះ រដ្ឋ ឬ ម្ចាស់គម្រោង ត្រូវតែយកអចលនវត្ថុដែលបានធ្វើអស្សាមិករណ៍ទាំងនោះ ទៅប្រើប្រាស់សម្រាប់គោលដៅដែលបានគ្រោងទុកនៅក្នុងគម្រោងអស្សាមិករណ៍តែមួយប៉ុណ្ណោះ ដើម្បីផលប្រយោជជាតិ និងផលប្រយោជសាធារណៈ។ រដ្ឋ ឬ ម្ចាស់គម្រោង មិនអាចទុកចោលនូវអចលនវត្ថុដែលធ្វើអស្សាមិករណ៍នោះឲ្យនៅទំនេរដោយគ្មានហេតុផលសមរម្យ ឬ ផ្ទេរទៅឲ្យតតិយជនណាម្នាក់ ដោយយកទៅប្រើប្រាស់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជនបាននោះឡើយ។ បើសិនរដ្ឋ ឬ ម្ចាស់គម្រោងទុកអចលនវត្ថុនោះឲ្យនៅទំនេរចោលដោយគ្មានហេតុផលសមរម្យ និងមិនអនុវត្តទៅតាមគម្រោងដែលបានគ្រោងទុកនោះ គឺអាចធ្វើឲ្យមានការប៉ះពាល់ដល់រាជរដ្ឋាភិបាល ដែលអាចធ្វើឲ្យមានការបាត់បង់ការទុកចិត្តពីសំណាក់ប្រជាពលរដ្ឋទៅលើរាជរដ្ឋភិបាល ហើយពេលខ្លះអាចបង្កឲ្យមានវិវាទរវាងប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាលផងដែរ។ ប៉ុន្តែ រដ្ឋក៏អាចទុកអចលនវត្ថុនោះឲ្យនៅទំនេរសិនក៏បាន បើក្នុងករណីដែលស្ថានភាពនៃការអនុវត្តគម្រោងមិនអំណោយផលដូចជា ក្នុងករណីប្រធានសក្តិ ឬ ស្ថានភាពផ្សេងៗដែលធ្វើឲ្យពុំអាចអនុវត្តនៅគម្រោងអស្សាមិករណ៍បាននោះ។

### ១.២.៣. ការទូទាត់សំណងនៃអស្សាមិករណ៍

ជាទូទៅ ការកំណត់អំពីចំនួនសំណងសមរម្យ និងយុត្តិធម៌ សម្រាប់គម្រោងនៃការធ្វើអស្សាមិករណ៍ដកហូតទ្រព្យសម្បត្តិឯកជន ក៏ដូចជាទ្រព្យសម្បត្តិសាធារណៈ នឹងមានការប្រែប្រួលខុសគ្នាយ៉ាងច្រើន។ ពីព្រោះ ក្នុងករណីនៃការទិញលក់ឯកជនដែលធ្វើឡើងរវាងភាគីមានសេរីភាពក្នុងការធ្វើសកម្មភាពទិញលក់ មានន័យថា អ្នកលក់អាចជ្រើសរើសបដិសេធមិនព្រមទទួលយកតម្លៃដែលអ្នកទិញស្នើឡើង ហើយមិនលក់ទ្រព្យនោះឲ្យអ្នកទិញបានយ៉ាងងាយ ចំណែកឯការធ្វើអស្សាមិករណ៍វិញវាប្រៀបនឹងករណីលក់ដោយបង្ខំ។

រាជរដ្ឋាភិបាលដែលជាភាគីអ្នកទិញ តាមរយៈគណៈកម្មាធិការអស្សាមិករណ៍ មានឥទ្ធិពលខ្ពស់ជាងភាគីអ្នកលក់ដែលជាប្រជាពលរដ្ឋ ដោយសារ រាជរដ្ឋាភិបាលមានភារកិច្ចការពារថវិកាជាតិ ដូចនេះ គណៈកម្មាធិការអស្សាមិករណ៍ ត្រូវមានការប្រយ័ត្នប្រយែងមិនឲ្យមានការផ្តល់សំណងហួសពីតម្លៃនៃអចលនវត្ថុដែលត្រូវដកហូតនោះឡើយ។ ប៉ុន្តែ ក្នុងការផ្តល់សំណង រាជរដ្ឋាភិបាល ក៏មានកាតព្វកិច្ច ក្នុងការផ្តល់ភាពយុត្តិធម៌ និងការពារសិទ្ធិលើទ្រព្យសម្បត្តិរបស់អ្នកលក់ដោយបង្ខំនោះផងដែរ។

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជ្រើសរើសគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យណាមួយឲ្យធ្វើការសិក្សាកំណត់អំពីថ្លៃទីផ្សារ ឬ ថ្លៃជំនួស ដែលការកំណត់នោះអាចជួយសម្រួលការងារមួយចំនួនដល់គណៈកម្មាធិការអស្សាមិករណ៍ ក្នុងការវាយតម្លៃដោយឥតលម្អៀង ចំពោះចំនួនទឹកប្រាក់ដែលជាសំណងដ៏សមរម្យ និងយុត្តិធម៌។ លើសពីនេះ ច្បាប់មានចែងពីមធ្យោបាយសម្រាប់ធ្វើការតវ៉ាអំពីកម្រិតចំនួនសំណង ជាបឋម គឺឲ្យប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា និងជាចុងក្រោយ គឺប្តឹងទៅតុលាការ។

### ក. គោលការណ៍នៃការផ្តល់សំណង

ជាទូទៅ គោលការណ៍នៃការផ្តល់សំណងត្រូវបានកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយដែលជ្រើសរើសដោយគណៈកម្មាធិការអស្សាមិករណ៍ គឺស្តង់ដារនៃការផ្តល់សំណងត្រូវគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួស នៅពេលនៃកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបានសំណងលើការខូចខាតចំពោះអចលនវត្ថុជាក់ស្តែងដែលមាន ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ដែលកាលបរិច្ឆេទចុងក្រោយ គឺសម្រាប់អ្នកមានសិទ្ធិទទួលបាននូវសំណងសមរម្យ និង យុត្តិធម៌។ ការសងសំណងតាមស្តង់ដារនៃការផ្តល់សំណងគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួស គឺជាវិធីសាស្ត្រមួយដែលធ្វើឲ្យការសងសំណងមានភាពយុត្តិធម៌ និងជាកត្តាមួយដែលអាចធ្វើឲ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិភាគច្រើន អាចទទួលយកនូវសំណងពីការធ្វើអស្សាមិករណ៍ដោយពេញចិត្ត។ *ថ្លៃជំនួស* ជាចំនួនដែលបុគ្គលម្នាក់ត្រូវចំណាយ ដើម្បីទទួលបាននូវទ្រព្យថ្មីមួយមកជំនួសឲ្យទ្រព្យចាស់ណាមួយនោះ ក្នុងពេលណាមួយជាក់លាក់ រីឯ *ថ្លៃទីផ្សារ* ជាតម្លៃព្រមព្រៀងគ្នារវាងអ្នកលក់ដែលមានឆន្ទៈលក់ និងអ្នកទិញដែលមានឆន្ទៈទិញ នៅក្នុងជីវភាពសាមញ្ញ គឺភាគីទាំងសងខាងមានភាពឯករាជ្យ។ ម្យ៉ាងទៀត ថ្លៃជំនួស គឺជាចំនួនដែលគណនាមុនពេលធ្វើការរើបអូស ដែលត្រូវការសម្រាប់ជំនួសទ្រព្យដែលរងផលប៉ះពាល់ ដោយគ្មានការដកចេញនូវចំនួនពន្ធ និង/ឬ ថ្លៃចំណាយលើចរន្តការ រួមមាន៖ ដីផលិតកម្ម ដីលំនៅឋាន ផ្ទះ សំណង់ ដំណាំរុក្ខជាតិដែលមិនទាន់កាប់ ដំណាំ និងដើមឈើដាំដុះតាមរដូវកាល និង ដើមឈើដែលដាំយកឈើ[១៩]។

[១៩] សៀវភៅច្បាប់អចលនវត្ថុនៅកម្ពុជា រៀបរៀងដោយ East-West management Institute.Inc នៅខែវិច្ឆិកា ឆ្នាំ២០១២ ជំពូកទី១១ ទំព័រទី៣៧៦

សំណាងត្រូវបានពិនិត្យមើលលើទ្រព្យពីរប្រភេទធំៗ គឺទ្រព្យរូបីយ និងទ្រព្យអរូបីយ ដែលមានស្តង់ដារផ្សេងៗគ្នាដែលត្រូវប្រើដើម្បីកំណត់អំពី សំណាងសមរម្យ និងយុត្តិធម៌ សម្រាប់ទ្រព្យប្រភេទផ្សេងៗគ្នាទាំងនេះ ចំពោះសំណាងសម្រាប់ទ្រព្យរូបីយ គឺមានលក្ខណៈងាយស្រួលយល់ជាងដោយសារមនុស្សភាគច្រើនសុទ្ធតែមានទ្រព្យរូបីយជាកម្មសិទ្ធិរបស់ខ្លួន ហើយធ្វើការទិញលក់ទ្រព្យរូបីយជាញឹកញាប់។ ស្តង់ដារនៃការផ្តល់សំណាង គឺសំណាងត្រូវគិតតាមថ្លៃជំនួស ឬ ថ្លៃទីផ្សារ ដែលថ្លៃទាំងពីរនេះ ត្រូវបានកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យណាមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍[២០]។ ប្រាក់សំណាងត្រូវគិតតាមតម្លៃសំណាងសរុប ដកចំនួនទឹកប្រាក់បន្ទុកពន្ធប្រថាប់ត្រា និង/ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនរដ្ឋដែលប្រាក់សំណាងមិនត្រូវបានគិតដល់ការប្រែប្រួលនៃតម្លៃ ក្រោយពីពេលដែលកើតមានចាប់ពីថ្ងៃចេញប្រកាសស្តីពីគម្រោងអស្សាមិករណ៍នោះឡើយ[២១]។ ហេតុផលក្នុងការចងបែបនេះ គឺដោយសារនៅពេលដែលសាធារណៈជនបានដឹងអំពីគម្រោងអស្សាមិករណ៍ តម្លៃដីនៅលើទីតាំងគម្រោងនោះអាចមានការកើនឡើង ឬ ថយចុះ[២២] ហើយសំណាងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួស ទៅតាមភាពជាក់ស្តែង ដោយមានការយល់ព្រមគ្នាពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ និងពីសំណាក់គណៈកម្មាធិការអស្សាមិករណ៍[២៣]។

### ខ. នីតិវិធីនៃការផ្តល់សំណង

បែបបទ និងនីតិវិធីនៃការទូទាត់សំណាង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញ វាក្យខណ្ឌទី១ នៃមាត្រា១៩ និងមាត្រា២១ នៃច្បាប់ស្តីពីអស្សាមិករណ៍ និងមាត្រា៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ តម្រូវឲ្យផ្តល់សំណាងសមរម្យ និងយុត្តិធម៌មុននឹងរដ្ឋធ្វើអស្សាមិករណ៍ដកហូតទ្រព្យសម្បត្តិឯកជន។

ច្បាប់ស្តីពីអស្សាមិករណ៍ មិនបានចែងច្បាស់លាស់អំពីរយៈពេលជាក់លាក់ដែលត្រូវផ្តល់សំណាងមុននឹងធ្វើអស្សាមិករណ៍នោះទេ។ សំណាងត្រូវផ្តល់ឲ្យយ៉ាងតិច ៣០ថ្ងៃមុនធ្វើការដកហូត

---

[២០] មាត្រា២២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[២១] មាត្រា២៥ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[២២] មាត្រា២៦ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[២៣] មាត្រា២៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

ជាអ្វីដែលច្បាប់នេះបានចែងគឺ ម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិ អាចកាន់កាប់ទីតាំងអចលនវត្ថុនោះបានត្រឹមរយៈពេល ១ខែ បន្ទាប់ពីទទួលបានសំណង។ ក្នុងអំឡុងពេលនោះ ម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិ ទទួលខុសត្រូវលើការថែរក្សាទ្រព្យនោះ រហូតដល់មានការទទួលយកអចលនវត្ថុនោះដោយគណៈកម្មាធិការអស្សាមិករណ៍។

ជាទូទៅ មិនមែនរាល់វត្ថុដែលរងផលប៉ះពាល់ទាំងអស់ នឹងយល់ព្រមទទួលយកនូវការវាយតម្លៃទ្រព្យដែលរាជរដ្ឋាភិបាលចាត់ចែងធ្វើ និងឯកភាពចំពោះចំនួនសំណងសរុបដែលពួកគេនឹងត្រូវទទួលបានពីរដ្ឋនោះទេ។ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមួយចំនួនអាចនឹងតវ៉ាថាដី និងទ្រព្យសម្បត្តិផ្សេងៗទៀតដែលមាន គឺថ្លៃលើសពីអត្រាដែលរាជរដ្ឋាភិបាល ដើម្បីឲ្យរាជរដ្ឋាភិបាលយល់ព្រមផ្ដល់សំណងឲ្យច្រើនជាងនេះ។

វិវាទទាំងនេះមួយចំនួនអាចមានលក្ខណៈស្មុគ្រស្មាញ ហើយការដោះស្រាយវិវាទនោះក៏ត្រូវការពេលវេលាយូរដែរ ជាពិសេសសម្រាប់គម្រោងធំៗដែលមានការប៉ះពាល់បុគ្គលច្រើននាក់។ ពេលខ្លះវាអាចនឹងមានរឿង ប្រសិនបើម្ចាស់អចលនវត្ថុមិនឯកភាពលើប្រាក់សំណងដែលរដ្ឋបានស្នើផ្ដល់ឲ្យ ហើយបដិសេធមិនទទួលយកការផ្ដល់សំណងនោះ ទោះជាមានវិវាទ រដ្ឋាភិបាលក៏មិនចាំបាច់ចាំរហូតដល់វិវាទចប់នោះទេ រដ្ឋាភិបាលអាចដំណើរការអនុវត្តគម្រោងដោយ ទោះបីមិនទាន់ដោះស្រាយរួចរាល់ក៏ដោយ។

ការតវ៉ាមួយនៅក្នុងចំណោមការតវ៉ាធំៗ ដែលកើតមានជាញឹកញាប់ ពាក់ព័ន្ធនឹងដីធ្លីដោយសារតែការធ្វើអស្សាមិករណ៍នោះគឺ ទាក់ទងនឹងការប៉ានប្រមាណតម្លៃទ្រព្យសម្បត្តិដែលរដ្ឋមានបំណង ចង់ដកហូត។ រាល់ការធ្វើអស្សាមិករណ៍ រាជរដ្ឋាភិបាលតែងតែចង់ចំណាយចរិកាតិចបំផុតតាមដែលអាចធ្វើទៅបានសម្រាប់ទ្រព្យដែលត្រូវដកហូតនោះ ដែលផ្ទុយនឹងម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិវិញ ដែលចង់បានប្រាក់សំណងច្រើនបំផុតតាមដែលអាចទាមទារ។ ភាគីម្ខាងៗអាចគិតថាការប៉ាន់ប្រមាណរបស់ខ្លួននូវតម្លៃទ្រព្យនោះ គឺមានលក្ខណៈ "សមរម្យ និងយុត្តិធម៌" ។ អ្វីដែលខុសប្លែកពីការទិញលក់ធម្មតា គឺថាបុគ្គលដែលជាម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ គ្មានជម្រើសចំពោះការលក់ ឬ ការរក្សាទុកនូវទ្រព្យរបស់ខ្លួនឡើយ ហេតុនេះ គូភាគីនៃការលក់ទ្រព្យដោយបង្ខំបែបនេះ មិនមានលក្ខណៈស្មើភាពគ្នាឡើយ។ ច្បាប់ស្ដីពីអស្សាមិករណ៍ មានចែងអំពីនីតិវិធីសម្រាប់ធ្វើការប្ដឹងតវ៉ាចំពោះការប៉ាន់ប្រមាណរបស់រាជរដ្ឋាភិបាលអំពីតម្លៃទ្រព្យ។ ក្នុងករណីខ្លះ ការដោះស្រាយចំពោះការប្ដឹងតវ៉ានោះអាចត្រូវចំណាយពេលរាប់ខែ ឬ រាប់ឆ្នាំ។

បើការអនុវត្តគម្រោងត្រូវរង់ចាំរហូតដល់វិវាទ ទាក់ទងនឹងសំណងនោះត្រូវបានដោះស្រាយចប់សព្វគ្រប់ ថ្លៃចំណាយលើការអនុវត្តគម្រោងនោះ អាចមានការកើនឡើងយ៉ាងខ្លាំង និងទទួលផលប្រយោជន៍ពីគម្រោងសាងសង់ផ្លូវថ្នល់ ឬ ផ្លូវរថភ្លើង ឬ ព្រលានយន្តហោះ ឬ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈផ្សេងៗនោះនឹងត្រូវពន្យាពេលផងដែរ។ ប្រាក់សំណង គឺជាបញ្ហាចំពោះមុខនៅក្នុងពេលនោះ ព្រោះថាកម្មវត្ថុនៃវិវាទ គឺទាមទារនូវការផ្តល់សំណងសមរម្យដែលអាចទទួលយកបានដែលមិនមែនជាតម្លៃទាបបំផុតនោះទេ ហើយការលក់ ឬ មិនលក់នូវអចលនវត្ថុនោះលែងជាបញ្ហាទៀតនោះឡើយ។

ដើម្បីជៀសវាងនូវការចំណាយថវិកាច្រើនដោយសារការពន្យាពេលអនុវត្តគម្រោង ច្បាប់ស្តីពីអស្សាមិករណ៍ បានចែងថា រាជរដ្ឋាភិបាលអាចបន្តធ្វើការដកហូតអចលនវត្ថុនោះបាន ទោះបីជាម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិ មិនឯកភាពទទួលយកនូវប្រាក់សំណងដែលបានស្នើផ្តល់ជូនដោយគណៈកម្មាធិការអស្សាមិករណ៍ ឬ ទទួលយកការផ្តល់ប្រាក់សំណងពីគណៈកម្មាធិការអស្សាមិករណ៍ ប៉ុន្តែ រក្សាសិទ្ធិក្នុងការប្តឹងតវ៉ាជាបន្តស្របតាមបញ្ញត្តិ មាត្រា៣៩ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ ២០១០។

# ជំពូកទី២

# ជំពូកទី២

# វិវាទក្នុងអស្សាមិករណ៍

វិវាទ គឺជាដំណើរទាស់ទែងគ្នា ឬ ដំណើរឈ្លោះប្រកែកគ្នា[២៤]។ វិវាទកើតមានឡើងតាមរយៈសកម្មភាពដែលបានប្រព្រឹត្តដោយចេតនា ឬ ដោយអចេតនាក្ដី។ យ៉ាងណាមិញ ដំណើរការនីតិវិធីក្នុងការធ្វើអស្សាមិករណ៍របស់រដ្ឋ តែងតែជួបនឹងការលំបាកមួយចំនួន ដោយតម្រូវឲ្យមានការសម្របសម្រួល និងផ្ដល់សំណងប្រកបដោយភាពសមរម្យ និងយុត្តិធម៌ ដើម្បីឲ្យដំណើរការអាចទៅមុខបានដោយរលូន។ វិវាទដែលកើតមានឡើងទាំងនោះ ដោយសារបញ្ហាប្រឈមនានាដែលបានកើតមានមុនពេលធ្វើអស្សាមិករណ៍ ឬ ក្នុងពេលធ្វើអស្សាមិករណ៍ ឬ ក្នុងការទូទាត់សំណងអស្សាមិករណ៍ ដូចនេះ ទាមទារឲ្យរាជរដ្ឋាភិបាលស្វែងរកដំណោះស្រាយចំពោះវិវាទទាំងនោះ។ ការដោះស្រាយវិវាទមានចែងនៅក្នុងជំពូកទី៦ នៃច្បាប់ស្ដីពីអស្សាមិករណ៍ ចែងនូវគោលការណ៍ជាមូលដ្ឋានមួយចំនួន និងនីតិវិធីសម្រាប់ការប្ដឹងតវ៉ា ដែលប្រជាពលរដ្ឋអាចប្រើនៅក្នុងដំណាក់កាលផ្សេងៗគ្នានៃវដ្ដគម្រោង។ មានតែ បីមាត្រាប៉ុណ្ណោះដែលចែងនៅក្នុងជំពូកនេះ ដូចនេះ សេចក្ដីលម្អិតភាគច្រើននឹងត្រូវមានចែងពន្យល់បន្ថែមនៅក្នុងអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងៗទៀតដែលណែនាំអនុវត្តច្បាប់នេះ ជាធម្មតា បញ្ហាប្រឈម និងដំណោះស្រាយទាំងឡាយដែលកើតមាន ឬ អាចកើតមាននៅក្នុងដំណើរការនៃការធ្វើអស្សាមិករណ៍ទាំងមូល តែងតែមានលើរាល់ការធ្វើអស្សាមិករណ៍នីមួយៗ។ តើបញ្ហាអ្វីខ្លះដែលកើតមានក្នុងការធ្វើអស្សាមិករណ៍? តើរាជរដ្ឋាភិបាលមានវិធីសាស្ត្រដូចម្ដេចខ្លះក្នុងការដោះស្រាយវិវាទទាំងនោះ? ដូចនេះ ក្នុងជំពូកទី២ ស្ដីពីវិវាទនៃអស្សាមិករណ៍ នឹងធ្វើការបកស្រាយអំពី**បញ្ហាប្រឈម** (២.១) និង**ដំណោះស្រាយ** (២.២)។

## ២.១. បញ្ហាប្រឈម

ការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា បានបង្កើតឲ្យមាន បញ្ហាជាច្រើន មិនត្រឹមតែរវាងរាជរដ្ឋាភិបាលជាមួយនឹងស្ថាប័នឯកជន ឬ ប្រជាពលរដ្ឋនោះទេ លើសពីនោះ គឺរវាងរាជរដ្ឋាភិបាលមានវិវាទជាមួយនឹងស្ថាប័នរដ្ឋដូចគ្នាផងដែរ។ រាល់ការធ្វើអស្សាមិករណ៍ តែងតែជួបនៅបញ្ហាជាច្រើន ដោយសារតែពាក់ព័ន្ធនឹងការដកហូតនូវសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋទៅលើអចលនវត្ថុ។ បញ្ហាជាច្រើនកើតឡើងនៅក្នុងដំណាក់កាលអនុវត្តគម្រោងអស្សាមិករណ៍ដោយសារ

[២៤] វចនានុក្រមខ្មែររបស់សម្ដេចសង្ឃ ជួន ណាត់ ឆ្នាំ២០១១

ភាពកើតទុក្ខមិនសុខចិត្តរបស់ប្រជាពលរដ្ឋ និងអាចធ្វើឲ្យមានបញ្ហាប៉ះពាល់ដល់មជ្ឈដ្ឋាននៅក្បែរនោះទៀតផង។ កត្តាទាំងនោះហើយដែលជះឥទ្ធិពលដល់ការបំពេញកាតព្វកិច្ចរបស់បុគ្គលិករដ្ឋ ឬអ្នកអនុវត្តគម្រោង ព្រមទាំងធ្វើឲ្យការអនុវត្តគម្រោងមានភាពយឺតយ៉ាវទៀតផង[២៥]។ ភាពដែលនាំឲ្យរាំងស្ទះទាំងអស់នេះហើយដែលបណ្តាលឲ្យការធ្វើអស្សាមិករណ៍នីមួយៗមានការប្តឹងតវ៉ា និងធ្វើឲ្យការអនុវត្តគម្រោងត្រូវចំណាយពេលវេលាកាន់តែច្រើនថែមទៀត។ តើបញ្ហាប្រឈមដែលកើតនៅក្នុងអស្សាមិករណ៍ត្រូវបានបែងចែកជាប៉ុន្មានប្រភេទ? ចំពោះបញ្ហាប្រឈមនេះ គឺភាគច្រើនកើតចេញពី **បញ្ហាប្រឈមរវាងរដ្ឋ និងទ្រព្យសម្បត្តិរបស់រដ្ឋ**(២.១.១) ក្រៅពីនោះគឺកើតចេញពី **បញ្ហារវាងរដ្ឋ និងប្រជាពលរដ្ឋ**(២.១.២)។

### ២.១.១. បញ្ហារវាងរដ្ឋ និងទ្រព្យសម្បត្តិរបស់រដ្ឋ

ដូចមានចែងនៅក្នុងមាត្រា៧ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០ បានចែងថា "មានតែរដ្ឋទេ គឺជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ដោយការធ្វើអស្សាមិករណ៍អាចអនុវត្តបាន លុះកណា យកទៅអនុវត្តគម្រោងដូចដែលមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ។ យ៉ាងណាមិញ ការធ្វើអស្សាមិករណ៍ គឺសម្តៅទៅលើការដកហូតអចលនវត្ថុដើម្បីយកមកអភិវឌ្ឍប្រទេសជាតិនិងបំរើផលប្រយោជន៍សាធារណៈ ដែលអចលនវត្ថុទាំងនោះ អាចជាទ្រព្យសម្បត្តិសាធារណៈ និង/ឬ ទ្រព្យសម្បត្តិឯកជន។ ដូចមានចែងក្នុងវាក្យខណ្ឌទី១ មាត្រ៥៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មានចែងថា *"ទ្រព្យសម្បត្តិសាធារណៈ ឬ ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ភ្នំ សមុទ្ទ បាតសមុទ្ទ ឆ្នេរសមុទ្ទ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថា ជារបស់រដ្ឋ។"* នៅពេលខ្លះការដកហូតទ្រព្យសម្បត្តិសាធារណៈ ក៏មិនប្រាកដថាជាការអនុវត្តដោយងាយស្រួលដូចជាទ្រឹស្តីដែលបានចែងក្នុងច្បាប់នោះដែរ ព្រោះម្ចាស់គម្រោងអស្សាមិករណ៍អាចបង្កឲ្យកើតមានបញ្ហា ដោយសារពុំបានអនុវត្តទៅតាមគម្រោងដែលបានដាក់ស្នើសុំទៅរាជរដ្ឋាភិបាល ឬ អនុវត្តខុសពីគម្រោងនោះ។ នេះហើយជាបញ្ហាប្រឈមមួយ ដែលរាជរដ្ឋាភិបាលពុំអាចទទួលយកបាន និងធ្វើឲ្យអ្នកផ្តល់ជំនួយពីបណ្តាសង្គមអន្តរជាតិបាត់បង់ទំនុកចិត្តក្នុងការផ្តល់ជំនួយ ដើម្បីអនុវត្តនូវគម្រោងអស្សាមិករណ៍នេះ។ បើសិនជា មានការបញ្ឈប់ក្នុងការផ្តល់ជំនួយ ដើម្បីធ្វើអស្សាមិករណ៍ នេះគឺជាបញ្ហាដ៏ធំមួយដែលធ្វើឲ្យយឺតយ៉ាវក្នុងការអនុវត្តគម្រោងអស្សាមិករណ៍ ឬ

---

[២៥] សៀវភៅសារណាអំពី គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើអស្សាមិករណ៍ ថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត ឆ្នាំ២០១២ ទំព័រទី២៦

ពេលខ្លះទៀតអាចឈានទៅដល់ការបោះបង់ គម្រោងអស្សាមិករណ៍ចោលក៏អាចថាបាន។ ពិតប្រាកដណាស់ ថវិកា គឺជាកត្តាដ៏សំខាន់ក្នុងការធ្វើអស្សាមិករណ៍ ព្រោះអស្សាមិករណ៍ត្រូវតែគ្រោងថវិកា ដើម្បីត្រៀមទុកក្នុងការផ្តល់សំណង រាល់គ្រប់សកម្មភាពដែលអាចកើតមាន។ នៅពេលអស្សាមិករណ៍ត្រូវបានផ្អាក ឬ បញ្ឈប់ ទាំងនេះជាហេតុផលយ៉ាងធំដែលបង្កឲ្យរាជរដ្ឋាភិបាលបានបាត់បង់ជំនឿចិត្តទៅលើម្ចាស់គម្រោងអស្សាមិករណ៍។

### ២.១.២. បញ្ហាប្រឈមរវាងរដ្ឋ និងប្រជាពលរដ្ឋ

បន្ទាប់ពី ធ្វើការបកស្រាយអំពីការដកហូតទ្រព្យសម្បត្តិសាធារណៈរួចហើយ ឃើញថាពិតជាអាចកើតមាននូវបញ្ហា។ ចំណែកឯ ការដកហូតទ្រព្យសម្បត្តិឯកជន វាមានភាពលំបាកកាន់តែខ្លាំងដោយសារតែបញ្ហាទាំងអស់គឺ កើតចេញពីប្រជាពលរដ្ឋដែលជាជនរងផលប៉ះពាល់ផ្ទាល់តែម្តង។ បញ្ហាជាច្រើនដែលបានកើតចេញពីការប្តឹងតវ៉ាសំណាក់ប្រជាពលរដ្ឋ ក៏ដោយសារតែភាពមិនសុខចិត្តក្នុងការទទួលយកនូវសំណងដែលបានសងទៅលើការខូចខាតរបស់ពួកគាត់។ បញ្ហាប្រឈមទាំងនេះកើតមានឡើង ដោយសារតែប្រជាពលរដ្ឋភាគច្រើនពុំយល់ដឹងច្បាស់លាស់ថាអ្វីគឺជាការធ្វើអស្សាមិករណ៍ និងភាពមិនអាចទទួលយកនូវសំណង ឬ ភាពមិនចង់បាត់បង់នូវទ្រព្យសម្បត្តិដែលខ្លួនមានប្រើសព្វថ្ងៃ។ ប្រជាពលរដ្ឋមួយចំនួនធំ ពួកគាត់តែងគិតថាអស្សាមិករណ៍នេះគឺជាការដកហូតសិទ្ធិស្របច្បាប់របស់ពួកគាត់ដែលទទួលបានស្របច្បាប់ពីរាជរដ្ឋាភិបាល ហើយហេតុអ្វីបានជាធ្វើការដកហូតវិញបែបនេះ។ ពេលខ្លះពួកគាត់ក៏អាចយកហេតុផលថាច្បាប់ស្តីពីអស្សាមិករណ៍នេះពួកគាត់ពុំបានដឹងពីមុនមក ហើយដោយសារតែការផ្សព្វផ្សាយអប់រំផ្នែកច្បាប់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពុំទាន់បានគ្រប់ជ្រុងជ្រោយ ដែលអាចឲ្យប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសអាចទទួលយកបាននោះឡើយ។ ណាមួយច្បាប់ស្តីពីអស្សាមិករណ៍ទើបតែចូលជាធរមាននៅឆ្នាំ ២០១០ ដែលពុំទាន់មានពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើឲ្យប្រជាពលរដ្ឋអាចដឹងអំពីគោលដៅ និងគោលបំណងរបស់ច្បាប់នេះបាន។

ចំពោះ ការទូទាត់សំណងវិញ ក៏តែងតែកើតមាននូវបញ្ហា ដែលបណ្តាលឲ្យប្រជាពលរដ្ឋមានការប្តឹងតវ៉ាអំពីការទូទាត់សំណងនេះផងដែរ ទោះបីការទូទាត់សំណងធ្វើឡើងតាមរយៈការកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯកជនណាមួយតាមតម្លៃទីផ្សារ ឬ ថ្លៃជំនួសក៏ដោយ។ ទោះបីជាលក្ខខណ្ឌក្នុងការផ្តល់សំណងមានលក្ខណៈល្អប្រសើរជាងមុនក្តី ក៏ប្រជាពលរដ្ឋនៅតែពុំអាចទទួលយកបានដដែល ដោយសារតែកង្វះការអប់រំផ្សព្វផ្សាយផ្នែកផ្លូវច្បាប់ និងមិនបានយល់ច្បាស់អំពី

គោលបំណងរបស់រាជរដ្ឋាភិបាល ថែមទាំង ពួកគាត់បានបាត់បង់នូវសិទ្ធិលើទ្រព្យសម្បត្តិដែលទទួលបានស្របច្បាប់ និងកាន់កាប់ជាបន្តបន្ទាប់គ្នាពីជីដូនជីតាមកម្ល៉េះ។ ប្រជាពលរដ្ឋមួយចំនួនមិនព្រមទទួលយកនូវសំណង ដោយពួកគាត់នៅតែបន្តគិតថាសំណងនេះ មិនសមទៅនឹងតម្លៃនៃទ្រព្យសម្បត្តិរបស់ពួកគាត់ដែលបានបាត់បង់ ជាពិសេសគឺ ផ្ទះដូនតា និងពិបាករកទីតាំងថ្មីដែលអាចប្រកបរបរចិញ្ចឹមជីវិតដូចកន្លែងដែលធ្លាប់រស់នៅរបស់ពួកគាត់មុនជាដើម។ កត្តាទាំងអស់នេះហើយជាហេតុបង្កឲ្យមានការរាំងស្ទះដល់ការអនុវត្តគម្រោងអស្សាមិករណ៍ ដែលជាជម្ងឺប្រចាំកាយចំពោះការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាក់ស្តែង អាគារប៊ូឌីញ"ស" ស្ថិតក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញដែលរដ្ឋមានបំណងក្នុងការធ្វើអស្សាមិករណ៍លើអាគារនេះតាំងពីឆ្នាំ២០១៥ ម្ល៉េះរួចហើយនោះ គឺប្រជាពលរដ្ឋក្នុងឆ្នាំនោះមិនយល់ព្រមឡើយ ប៉ុន្តែបើធ្វើការក្រឡេកមកមើល ការដោះស្រាយដោយអភិបាលក្រុងភ្នំពេញ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងឆ្នាំ២០១៦ ឈានចូលឆ្នាំ២០១៧នេះវិញ មានត្រឹមតែប្រជាពលរដ្ឋប្រហែល៦% នៃចំនួនម្ចាស់សហកម្មសិទ្ធិសរុបដែលមិនទាន់ធ្វើការសម្រេចចិត្ត ដោយសារពុំសូវពេញចិត្តនឹងការកំណត់តម្លៃនេះ ដោយពួកគាត់និយាយថាតម្លៃសំណងគួរតែមានការប្រែប្រួល ឬ ឡើងតម្លៃ រវាងសហកម្មសិទ្ធិករដែលរស់នៅជាន់លើ និងសហកម្មសិទ្ធិករដែលរស់នៅជាន់ផ្ទាល់ដី ព្រោះការបង់ពន្ធក៏បានភាពខុសគ្នាផងដែរ ម្យ៉ាងទៀតចំពោះប្រជាពលរដ្ឋដែលបានធ្វើការតយ៉ាបដំបូលរស់នៅចេញពីអាគារជាច្រើនឆ្នាំ ក៏បានទាមទារសំណងដូចប្រជាពលរដ្ឋដែលរស់នៅក្នុងអាគារផងដែរ[២៦]។ ចំពោះករណីដែលបានកើតមាននៅក្នុងខេត្តកណ្តាល ដោយប្រជាពលរដ្ឋមួយគ្រួសារ ក្នុងចំណោមគ្រួសារមួយចំនួនធំទៀតដែលរងគ្រោះដោយសារការអភិវឌ្ឍស្ពានខាងស្តាំស្ពានព្រែកក្តាម បានប្តឹងតវ៉ាជំទាស់ទៅនឹងការផ្តល់សំណងពីអាជ្ញាធរ ដែលមានភាពមិនច្បាស់លាស់ និងមិនស្របទៅតាមតម្លៃទីផ្សារដែលទាបបំផុតផងនោះ។ អ្នកស្រី សូ ផល្លីយ៉ា ដែលជាជនរងអស្សាមិករណ៍រស់នៅភូមិទួលងោក ឃុំកំពង់ហ្លួង ស្រុកពញាឮខេត្តកណ្តាល មានប្រសាសន៍ថា គម្រោងសាងសង់ស្ពានខាងជើងស្ពានព្រែកក្តាមនេះ បានប៉ះចំទៅលើលំនៅដ្ឋាន របស់គាត់ទាំងស្រុង ដែលជាការព្រួយបារម្ភថា គម្រោងនេះនឹងធ្វើឲ្យ បាត់បង់ដីធ្លី និងផ្ទះសម្បែង ព្រមទាំង របរលក់ដូរនៅមុខផ្ទះទាំងអស់តែម្តង។ ដោយសារមានការទាមទារ ពីគ្រួសាររងគ្រោះខាងលើបានធ្វើការទាមទារសំណងទៅតាមតម្លៃទីផ្សារ ដែលទាបបំផុត ម្ចាស់ផ្ទះខាងលើអះអាងថា ដីនិងលំនៅដ្ឋានទំហំ១០ម៉ែត្រគុណនឹង១៥ម៉ែត្រ យ៉ាងទាបបំផុតមាន តម្លៃ

[២៦] សារព័ត៌មានរបស់ពលរដ្ឋ (People News) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ម៉ោង១៦:៤០នាទី ដោយ ពិ ជ័យ

៣៨០០០ដុល្លារ ប៉ុន្តែបែរជាអាជ្ញាធរខេត្តផ្តល់សំណងត្រឹមតែ១ម៉ឺនដុល្លារ និងដីមួយកន្លែងនៅទីតាំងផ្សេង ប៉ុន្តែ មិនទាន់បញ្ជាក់ច្បាស់ថាដីផ្តល់សំណងនោះ មានទីតាំងនៅចំណុចណានៅឡើយ ដោយម្ចាស់ផ្ទះរងគ្រោះអះអាងថា គ្រួសារគាត់មិនជំទាស់ទៅនឹងគម្រោងអភិវឌ្ឍន៍របស់រដ្ឋាភិបាលនោះទេ តែសុំការអភិវឌ្ឍន៍ផ្តល់សំណងសមរម្យតែប៉ុណ្ណោះ[២៧]។

ដោយឡែក នៅក្នុងករណីវិវាទក្នុងគម្រោងសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២វិញ ប្រជាពលរដ្ឋនៅក្នុងសហគមន៍មកពីឃុំចំនួនបី គឺឃុំស្រែគរ ឃុំក្បាលរមាស និងឃុំភ្លុក បានធ្វើការតវ៉ានៅក្នុងការឈូសឆាយសម្អាតផ្ទៃអាង។ មូលហេតុនៃធ្វើការតវ៉ា ព្រោះប្រជាពលរដ្ឋមិនចង់ឲ្យធ្វើការឈូសឆាយយកព្រៃកក់ខ្មោចសពដូនតារបស់ពួកគាត់ ដោយពួកគាត់គិតថាលុយពុំអាចដោះដូរបានឡើយ។ ក្នុងនោះ តួលេខរបស់គណៈកម្មការដោះស្រាយសំណងផលប៉ះពាល់ពីគម្រោងសាងសង់ទំនប់វារីអគ្គិសនីរហូតបច្ចុប្បន្នប្រជាពលរដ្ឋជាង ១២ភាគរយ ក្នុងចំណោមប្រជាពលរដ្ឋរងផលប៉ះពាល់ជាង ១ពាន់គ្រួសារមិនទាន់យល់ព្រមទទួលសំណង។ ក្នុងនោះប្រជាពលរដ្ឋភូមិស្រែគរ១ និងស្រែគរ២ មានចំនួនជាង ៩០គ្រួសារ និងភូមិក្បាលរមាស ជាង ៣០គ្រួសារ[២៨]។

## ២.២. ការដោះស្រាយវិវាទអស្សាមិករណ៍

ដោយសារតែភាពមិនចុះសម្រុងគ្នាក្នុងការធ្វើអស្សាមិករណ៍រវាងរដ្ឋ ជាមួយនឹងទ្រព្យសម្បត្តិសាធារណៈ ឬ ទ្រព្យសម្បត្តិឯកជននេះហើយជាហេតុបង្កឲ្យច្បាប់ស្តីពីអស្សាមិករណ៍ចែងប្រការជាមុននូវដំណោះស្រាយ និងបង្កើតគណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ ដំណើរការបណ្តឹង ត្រូវការដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការអស្សាមិករណ៍ក្នុងករណីគ្មានការដោះស្រាយប្រកបដោយការពេញចិត្តពីប្រពលរដ្ឋ ឬ អ្នកខូចប្រយោជន៍ទេនោះ អ្នកតវ៉ាអាចដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីអស្សាមិករណ៍។

សម្រាប់បញ្ហាពាក់ព័ន្ធនឹងសិទ្ធិ ឬ ផលប្រយោជន៍នានាលើដី ឬ ទ្រព្យដែលរងផលប៉ះពាល់ដោយសារគម្រោង ដែលជាបញ្ហាសំខាន់ដូចគ្នានឹងបញ្ហាសំណងដែរ ដោយសារការគណនាសំណងនឹងត្រូវធ្វើឡើង ផ្អែកលើប្រភេទនៃសិទ្ធិលើទ្រព្យដែលរងផលប៉ះពាល់នោះម្ចាស់អចលនវត្ថុ

[២៧] កាសែតកម្ពុជាថ្មី ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ដោយ រាំបូរ

[២៨] សារព័ត៌មានរបស់វិទ្យុអាស៊ីសេរី RFA ចុះផ្សាយថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ដោយ រដ្ឋា វិសាល

ឬ ម្ចាស់សិទ្ធិ នឹងត្រូវបានផ្តល់ឱកាសជាដំបូងឲ្យជម្រាបអំពីការទាមទារសិទ្ធិរបស់ខ្លួន ទៅក្រុមអ្នកស៊ើបអង្កេតសាធារណៈ ដែលចាត់តាំងដោយគណៈកម្មាធិការអស្សាមិករណ៍។ តើការដោះស្រាយចំពោះការធ្វើអស្សាមិករណ៍មានអ្វីខ្លះ? តើដំណោះស្រាយនីមួយៗមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចខ្លះ? តើនរណាខ្លះជាអ្នកដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ? តើការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ ត្រូវគោរពលក្ខខណ្ឌអ្វីខ្លះ?

ដូចនេះ ផ្នែកការដោះស្រាយវិវាទអស្សាមិករណ៍ នឹងធ្វើការបកស្រាយ ពីរចំណុច គឺ **ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (២.២.១)** និង**ការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ (២.២.២)**។

### ២.២.១. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

មុននឹងឈានទៅដល់ការដោះស្រាយវិវាទតាមផ្លូវតុលាការ គូបដិបក្សគប្បីជ្រើសរើសយកការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាមុនសិន។ ក្នុងនោះ ការដោះស្រាយក្រៅប្រព័ន្ធតុលាការគឺត្រូវដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយតាមរយៈគណៈកម្មាធិការអស្សាមិករណ៍ និងតាមរយៈគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា[២៩]។

ដោយអនុលោមតាមមាត្រា៣៣ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០ បានបញ្ញត្តិថា *"ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលមិនយល់ព្រមនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា"*។ តាមរយៈមាត្រានេះ បានបញ្ជាក់ឲ្យឃើញថា ចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គណៈកម្មាធិការអស្សាមិករណ៍មានឋានានុក្រមទាបជាងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ ចំពោះករណីខ្លះទៀត ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចប្តឹងដោយផ្ទាល់ទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាដោយមិនចាំបាច់ប្តឹងតវ៉ាទៅគណៈកម្មាធិការអស្សាមិករណ៍ជាមុនបាន ប៉ុន្តែ ករណីដែលច្បាប់បានកំណត់ពាក្យបណ្តឹង ត្រូវដាក់ជូនដោយផ្ទាល់ទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាតែម្តង។ បានសេចក្តីថា ប្រសិនបើការទាមទាររបស់ប្រជាពលរដ្ឋមិនត្រូវបានកត់ត្រាត្រឹមត្រូវ ឬ មានកង្វះចន្លោះនៅក្នុងកំណត់ត្រាអង្កេតនោះ ដោយសារហេតុផលណាមួយ អ្នកដែលទាមទារសិទ្ធិនោះ គួរគិតពីមធ្យោបាយសមស្របក្នុងការនាំបញ្ហានោះទៅជម្រាបដល់ គណៈកម្មាធិការអស្សាមិករណ៍។ ប្រសិនបើ បន្ទាប់ពីរយៈពេលសមរម្យមួយ ហើយនៅតែមិនបានទទួលការឆ្លើយតប ឬ សេចក្តី

[២៩] មាត្រា៣២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

សម្រេច គួរជាទីពេញចិត្តណាមួយពីគណៈកម្មាធិការអស្សាមិករណ៍ទេនោះ ជនរងផលប៉ះពាល់ដោយសារអស្សាមិករណ៍នោះអាចដាក់ពាក្យបណ្តឹង ជូនទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ក្នុងអំឡុងពេលដែលច្បាប់បានកំណត់ជាក់លាក់។

បុគ្គលដែលមានសមត្ថកិច្ចស្របតាមច្បាប់ដែលត្រូវត្រួតពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ារបស់ម្ចាស់អចនលវត្ថុ ឬ ម្ចាស់សិទ្ធិក្នុងការធ្វើអស្សាមិករណ៍ គឺគណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ ប៉ុន្តែ ក្នុងករណីដែលមិនមានការយល់ព្រម ចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់សិទ្ធិ និង/ឬ ម្ចាស់អចលនវត្ថុ អាចប្តឹងទៅតុលាការមានសមត្ថកិច្ចបាន។

ដោយបណ្តឹងសុំឲ្យមានការអង្កេតរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលដំណើរការនីតិវិធីនៃបណ្តឹងនេះគឺដូចជា បន្ទាប់ពី ទទួលបាននូវសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ព្រមទៅនឹងសេចក្តីប្រកាសរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចធ្វើពាក្យបណ្តឹងស្នើសុំឲ្យមានការអង្កេត ដែលបណ្តឹងនេះគឺត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យមានភាពច្បាស់លាស់នៃបណ្តឹងនោះ។ ទាក់ទងនឹងបណ្តឹងសុំឲ្យមានការអង្កេតនេះ ភាគីត្រូវធ្វើឡើងក្នុងកំឡុងពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការងារដោយគិតចាប់ពីថ្ងៃដែលទទួលសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។

នៅក្នុងករណី ចំពោះពាក្យបណ្តឹងដែលភាគីខាងប្រជាពលរដ្ឋបានដាក់ ពុំមានភាពត្រឹមត្រូវគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាត្រូវច្រានចោលនូវពាក្យបណ្តឹងនោះ ត្រូវបញ្ជូនទៅឲ្យភាគីនៃបណ្តឹងនោះវិញ ដើម្បីឲ្យដឹងថាពាក្យបណ្តឹងរបស់ខ្លួន ត្រូវបានគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាច្រានចោល ប៉ុន្តែ បើគណៈកម្មាធិការបានពិនិត្យមើលលើទម្រង់នៃពាក្យបណ្តឹង ហើយកម្មវត្ថុនៃពាក្យបណ្តឹងនោះមានលក្ខណៈត្រឹមត្រូវនោះ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាត្រូវចាត់វិធានការបើកការអង្កេតសារឡើងវិញ។ ក្រោយពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងកំឡុងពេល ៣០ថ្ងៃនៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាត្រូវធ្វើរបាយការណ៍ដែលក្នុងនោះត្រូវលើកនូវអនុសាសន៍ និងសុំការសម្រេចពីសំណាក់រាជរដ្ឋាភិបាល។ ដោយផ្អែកលើ ការសម្រេចរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាត្រូវចេញនូវសេចក្តីសម្រេចរបស់ខ្លួនចំពោះបណ្តឹងរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយ

បណ្តឹងតវ៉ា ត្រូវបញ្ជូនទៅឲ្យភាគីដែលដាក់ពាក្យបណ្តឹង ដើម្បីឲ្យដំណឹងអំពីអត្ថន័យរបស់សេចក្តីសម្រេចនោះ។

ជាក់ស្តែង អាគារប៊ូឌីញ"ស" ត្រូវបានរាជរដ្ឋាភិបាលធ្វើការដកហូតពីប្រជាពលរដ្ឋដោយជោគជ័យក្នុងឆ្នាំ២០១៧ ដោយឡែក កាលពីឆ្នាំ២០១៥កន្លងទៅ ការដកហូតនេះក៏ធ្លាប់កើតមានឡើងដែរ ប៉ុន្តែមិនបានសម្រេចនោះទេ។ ក្រឡេកមកឆ្នាំ២០១៧ ដំបូងឡើយ ប្រជាពលរដ្ឋបដិសេធលើការធ្វើអស្សាមិករណ៍នេះដូចគ្នា ប៉ុន្តែស្ថិតនៅក្រោមដំណោះស្រាយរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រួមជាមួយនឹងអន្តរក្រសួង ដែលបានផ្តល់ឲ្យប្រជាពលរដ្ឋក្នុងអាគារប៊ូឌីញ"ស" ដោយតម្លៃបន្ទប់ ១៤០០ដុល្លាអាមេរិកក្នុងមួយម៉ែត្រការ៉េ គឺជាតម្លៃមួយខ្ពស់ និងសមស្របជាមួយនឹងស្ថានភាពអាគារប៊ូឌីញដែលកំពុងចាស់ទ្រុឌទ្រោមស្រាប់[៣០]។

### ២.២.២. ការដោះស្រាយក្នុងប្រព័ន្ធតុលាការ

យោងតាមមាត្រា៣៤ នៃច្បាប់ស្តីអស្សាមិករណ៍ ឆ្នាំ២០១០ ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតអចលនវត្ថុណាមួយ ដែលមិនបានយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និងការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ។ ដោយផ្អែកលើការបញ្ញត្តិក្នុងមាត្រានេះ ការប្តឹងតាមផ្លូវតុលាការដាច់ខាតត្រូវតែចូលក្នុងលក្ខខណ្ឌណាមួយខាងលើនេះ ដោយលក្ខខណ្ឌទីមួយ (នីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនត្រឹមត្រូវ) ពាក់ព័ន្ធនឹងបញ្ហាខកខានមិនបានជូនដំណឹងដល់អាជ្ញាធរ ឬ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិត្រឹមត្រូវ។ ចំពោះលក្ខខណ្ឌទីពីរ (ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ) ពាក់ព័ន្ធនឹងគម្រោងនេះ គឺជនរងផលប៉ះពាល់អាចប្តឹងឲ្យធ្វើការស៊ើបអង្កេត ដើម្បីកំណត់អំពីលក្ខណៈនៃគម្រោងទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ ក្នុងករណីលើកលែង បើសិនម្ចាស់អចលវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនអាចធ្វើពាក្យណ្តឹងតវ៉ាសុំឲ្យមានការអង្កេតបានទេ ចំពោះតម្រូវការសម្រាប់កិច្ចអភិវឌ្ឍផ្លូវជាតិធំៗ ស្ពាន ផ្លូវរថភ្លើង ការតភ្ជាប់ ការចែកចាយបណ្តាញទឹក ភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកខ្វក់ ខ្សែបណ្តាញ ឬ លូមេបង្ហូរទឹក ប្រព័ន្ធធារាសាស្ត្រ។ លក្ខខណ្ឌទីបី (ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និងយុត្តិធម៌) ពាក់ព័ន្ធនឹងការគណនា

---

[៣០] សារព័ត៌មានរបស់វិទ្យុបារាំង RFI ចុះផ្សាយថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៧ ដោយ អេង គីមហុង

ចំនួន និងលក្ខណៈសម្បត្តិរបស់ជនរងប៉ះពាល់អស្សាមិករណ៍ដែលនឹងត្រូវទទួលបានសំណង[៣១]។ ម្យ៉ាងទៀត ដីកាសម្រេចរបស់តុលាការ គឺជាដីកាសម្រេចបិទផ្លូវតវ៉ា គឺបានសេចក្ដីថាបណ្ដឹងរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនអាចប្រព្រឹត្តទៅក្រៅប្រព័ន្ធតុលាការម្ដងទៀតវិញនោះទេ។

ដោយសមត្ថភាពជាភាគីក្នុងការធ្វើបណ្ដឹង គឺត្រូវធ្វើឡើងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងការធ្វើបណ្ដឹង គឺបុគ្គលដែលមានសិទ្ធិ និងករណីយកិច្ចតាមបញ្ញត្តិនៃច្បាប់។ ចំពោះម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពដោយខ្លួនឯងទៅតាមបញ្ញត្តិនៃច្បាប់ អាចដាក់ពាក្យបណ្ដឹងដោយខ្លួនឯងទៅកាន់គណៈកម្មាធិការដែលមានសមត្ថកិច្ចក្នុងការដោះស្រាយនូវបណ្ដឹងតវ៉ា។ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចធ្វើសកម្មភាពដែលទាក់ទងនឹងបណ្ដឹងតាមរយៈអ្នកតំណាងដោយអាណត្តិ ដែលខ្លួនបានជ្រើសរើសបានផងដែរ។ អ្នកតំណាងដោយអាណត្តិ ចាំបាច់ត្រូវមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដើម្បីធ្វើសកម្មភាពបណ្ដឹង ហើយសកម្មភាពណាមួយ ដែលអ្នកតំណាងដោយអាណត្តិបានធ្វើដោយគ្មានការយល់ស្របពីសំណាក់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ គឺសកម្មភាពទាំងនោះនឹងមិនមានអនុភាពឡើយ។ ដូចនេះ អ្នកតំណាងដោយអាណត្តិ ត្រូវតែទទួលបានសិទ្ធិពិសេសពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដើម្បីធ្វើសកម្មភាពក្នុងការប្ដឹងដូចជាទៅលើ ការដាក់ពាក្យបណ្ដឹង ការផ្សះផ្សារ ការលះបង់ការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ហើយរាល់សកម្មភាពរបស់អ្នកតំណាងដោយអាណត្តិនេះត្រូវចាត់ជាសកម្មភាពរបស់គូភាគី[៣២]។ ក្នុងលិខិតនៃពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់នូវចំនុចដូចជា ឈ្មោះម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាសយដ្ឋាន និងលេខទូរស័ព្ទ មូលហេតុនៃការធ្វើពាក្យបណ្ដឹង ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិនៅលើទឹកដីដែលត្រូវដកហូតនេះ នៅក្នុងពាក្យបណ្ដឹងភាគីនៃពាក្យបណ្ដឹងនេះ គប្បីសរសេរបញ្ជាក់ឲ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

យោងតាមអត្ថបទសារព័ត៌មានរបស់វិទ្យុអាស៊ីសេរី RFA ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ ដោយ រដ្ឋា វិសាល បានបង្ហាញឲ្យឃើញថា ទីតាំងដីចាំជំឡូងមួយកន្លែងដែលគ្រប់គ្រងដោយក្រុម

[៣១] សៀវភៅច្បាប់អចលនវត្ថុនៅកម្ពុជា រៀបរៀងដោយ East-West management Institute.Inc នៅខែវិច្ឆិកា ឆ្នាំ២០១២ ជំពូកទី១១ ទំព័រទី៣៩១

[៣២] មាត្រា៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សហាគមន៍ជនជាតិដើមភាគតិចប្រមាណ ១០គ្រួសារ នៅភូមិឡាម៉េះ ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌល ត្រូវបានលោកមេបញ្ជាការយោធាស្រុកដកហូតយកដោយបានបញ្ជាឲ្យកងទាហាន ចូលទៅដោតបង្គោលទង់ជាតិ និងសង់រោងប្រក់សំពត់កៅស៊ូលើទីតាំងនោះ គឺពុំមានឯកសារអ្វីបញ្ជាក់អំពីការចូលមកបោះទីតាំងនោះផងដែរ។ ក្នុងករណីនេះ ប្រជាពលរដ្ឋដែលជាជនរងផលប៉ះពាល់អស្សាមិករណ៍ អាចដាក់ពាក្យបណ្ដឹងដោយខ្លួនឯងផ្ទាល់ ឬ តាមរយៈអ្នកតំណាងទៅកាន់តុលាការដើម្បីធ្វើការស៊ើបអង្កេត ព្រោះថាការដកហូតនេះពុំមានការបង្កើតគណៈកម្មាធិការណាមួយនោះទេ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុវត្តឲ្យស្របតាមគោលដៅ និងគោលបំណងនៃច្បាប់ស្តីពីអស្សាមិករណ៍ ដែលបានអនុម័ត នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ និងចូលជាធរមាននៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ដោយរដ្ឋសភាដែលមាន ៨ជំពូក និង៣៩មាត្រា។ ច្បាប់ស្តីអស្សាមិករណ៍ ត្រូវបានបង្កើតឡើងក្នុងគោលដៅកំណត់អំពីគោលការណ៍ យន្តការ នីតិវិធីអស្សាមិករណ៍ និងសំណងឲ្យបានសមរម្យ និងយុត្តិធម៌ ដូចមានចែងក្នុងមាត្រា១ នៃច្បាប់នេះ។ បន្ថែមលើនេះ មាត្រា២ នៃច្បាប់ដដែល មានគោលបំណងធានានូវការដកហូតសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជន ធានាដល់ការទូទាត់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ និងបម្រើដល់ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ ការដកហូតដីធ្លីពីម្ចាស់អចលនវត្ថុ ឬ ម្ចាស់សិទ្ធិស្ថិតក្រោមរូបភាពជាអស្សាមិករណ៍ ដាច់ខាតត្រូវតែស្ថិតក្នុងការកំណត់នៃមាត្រា៥ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០ ពីចំណុចក ដល់ ចំណុចណ (១៥ចំណុច)។

ការធ្វើអស្សាមិករណ៍ដែលអនុលោមទៅតាមរបៀប និងដំណើរការនីតិវិធីដែលបានកំណត់ក្នុងច្បាប់ស្តីពីអស្សាមិករណ៍ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ គឺពិតជាបានរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដើម្បីបម្រើដល់ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ដែលរាជរដ្ឋាភិបាលបានអនុវត្តជាជំហានៗ និងទទួលបានជោគជ័យជាបន្តបន្ទាប់ មានន័យថា ក្នុងកិច្ចការប្រព្រឹត្តទៅនៃការអភិវឌ្ឍន៍បណ្តាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងប្រទេស ក៏ទទួលជោគជ័យ ហើយប្រជាពលរដ្ឋក៏ទទួលបានសំណងសមរម្យ និងយុត្តិធម៌ ដោយមានការគិតតាមតម្លៃទីផ្សារ (តម្រូវឲ្យមានអ្នកជំនាញធ្វើការវាយតម្លៃអចលនវត្ថុ) និងថ្លៃជំនួស (តម្រូវឲ្យរាជរដ្ឋាភិបាលផ្តល់ជាអចលនវត្ថុនៅកន្លែងទីទៃ ឬ វត្ថុណាមួយដែលមានតម្លៃស្មើ ដើម្បីជាថ្នូរក្នុងការដោះដូរ) រួមទាំងការផ្តល់ត្រឡប់ទៅវិញនូវហេដ្ឋារចនាសម្ព័ន្ធថ្មីដែលល្អប្រសើរ សម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ដែលទទួលរងអស្សាមិករណ៍ ក៏ដូចជាប្រយោជន៍របស់សង្គមជាតិទាំងមូល ។

ថ្វីត្បិត ការអនុវត្តកន្លងមករបស់សាលារាជធានីភ្នំពេញពុំបានអនុវត្តទៅតាមយន្តការ និងនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីអស្សាមិករណ៍ឲ្យបានទាំងស្រុងមែនពិត ប៉ុន្តែយន្តការមួយចំនួនត្រូវបានអនុវត្តមានលក្ខណៈសមស្រប ដែលផ្តល់ឱកាសឲ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិបានជួបពិភាក្សាលើកជាមតិយោបល់ ដើម្បីដោះស្រាយនូវបញ្ហានានាពាក់ព័ន្ធនឹងសំណងចំពោះអាគារ ដីធ្លី

ផ្ទះសម្បែង ដីដាំដុះដំណាំ ជាមួយភាគីរដ្ឋដែលជាម្ចាស់គម្រោងតាមរយៈការបង្កើតគណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដែលមានតួនាទីក្នុងការសម្របសម្រួលដោះស្រាយនូវផលប៉ះពាល់ទាំងឡាយ ដែលកើតមានក្នុងគម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ។ ជាក់ស្តែង កន្លងមកវិវាទអស្សាមិករណ៍ត្រូវបានដោះស្រាយដោយទទួលបានជោគជ័យជាបន្តបន្ទាប់ ក្នុងនោះ វិវាទដែលមានការដោះស្រាយមិនទាន់រួចរាល់នៅមានចំនួនតិចតួចប៉ុណ្ណោះ ដោយសារតែម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមួយចំនួនតូចធ្វើការបដិសេធមិនព្រមទទួលយកសំណងដែលរាជរដ្ឋាភិបាលបានផ្តល់ជូននោះទេ ប៉ុន្តែបញ្ហាឧបសគ្គរាំងស្ទះទាំងនោះនឹងត្រូវបានដោះស្រាយជាអន្លើតាមរយៈក្រៅប្រព័ន្ធតុលាការ និងក្នុងប្រព័ន្ធតុលាការ។

ទោះបីជា ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិបានទទួលយកប្រាក់សំណងរួចហើយក្តី ប៉ុន្តែជនរងផលប៉ះពាល់នៅតែអាចប្តឹងជំទាស់បានជានិច្ច ដោយលើកនូវហេតុផលសមរម្យក្នុងការតវ៉ាជាមួយនឹងរដ្ឋ។ ក្នុងនោះមាត្រា១៩ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០ បានបញ្ញត្តិថា *"ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី។"* ដូចនេះ ការប្តឹងជំទាស់ និងការដោះស្រាយនៅតែបន្តកើតមានក្នុងកំឡុងពេលការដកហូតកំពុងប្រព្រឹត្តទៅលើតំបន់អស្សាមិករណ៍ ប្រសិនបើ បុគ្គលណាដែលធ្វើឲ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងដែលបម្រើឲ្យផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែ ដល់ ១ឆ្នាំ និងពិន័យជាទឹកប្រាក់ពី ១សែនរៀល ដល់ ២លានរៀល ដូចបានកំណត់ក្នុងមាត្រា៣៦ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០។

# អនុសាសន៍

# អនុសាសន៍

យោងតាមការបកស្រាយខាងលើនេះ ចំពោះដំណើរការនីតិវិធីនៃការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិតជាជួបនឹងផលវិបាកយ៉ាងខ្លាំង ព្រោះមានបញ្ហាប្រឈមជាច្រើនដែលបានកើតឡើង ហើយភាគច្រើនបញ្ហាប្រឈមទាំងនោះគឺជារឿងដដែលៗ ទោះបីជា ការធ្វើអស្សាមិករណ៍នេះ ត្រូវបានធ្វើឡើងដើម្បីអភិវឌ្ឍប្រទេសជាតិ និងបម្រើផលប្រយោជន៍សាធារណៈក៏ពិតមែន ប៉ុន្តែ សំណង និងបញ្ហាផ្សេងៗដែលប្រជាពលរដ្ឋទាមទារតែងតែកើតមានរហូត។ ម្យ៉ាងវិញទៀត បញ្ហាទាំងនោះបានបង្កឲ្យមានការរាំងស្ទះដល់ដំណើរការនីតិវិធីនៃការធ្វើអស្សាមិករណ៍ ហើយចំណាយពេលវេលា និងថវិកាយ៉ាងច្រើនទៀតផង។

ដើម្បីដោះស្រាយនឹងបញ្ហាប្រឈមដែលកើតមានឡើង ក្រុមរបស់ខ្ញុំសូមមានមតិយោបល់ដូចតទៅៈ

– សូមអំពាវនាវដល់ប្រជាពលរដ្ឋដែលរស់នៅ ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាយកចិត្តទុកដាក់ដោយធ្វើការស្វែងយល់បន្ថែមឲ្យបានច្រើន ពាក់ព័ន្ធច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០ និងស្វែងយល់អំពីនីតិវិធីនៃការសងសំណងផងដែរ។

– សូមអំពាវនាវដល់រាជរដ្ឋាភិបាល សូមធ្វើការផ្សព្វផ្សាយអប់រំបន្ថែម ចំពោះច្បាប់ស្តីពីអស្សាមិករណ៍ឲ្យកាន់តែទូលំទូលាយ ដូចជាការផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ ផ្ទាំងផ្សព្វផ្សាយព័ត៌មាន។ល។

– សូមអំពាវនាវដល់ម្ចាស់គម្រោងអស្សាមិករណ៍ សូមសិក្សាឲ្យបានល្អិតល្អន់គ្រប់ជ្រុងជ្រោយទៅលើផលប្រយោជន៍ និងផលប៉ះពាល់សម្រាប់ការធ្វើអស្សាមិករណ៍ ជៀសវាងការចំណាយពេលវេលា និងថវិកាច្រើនលើសពីគម្រោងដែលបានគ្រោងទុក។ ដូចនេះ សូមពង្រឹងដល់ការផ្សព្វផ្សាយអប់រំ និងពន្យល់បន្ថែមដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹងអំពីការធ្វើអស្សាមិករណ៍នេះផង។

# ឯកសារយោង

# ឯកសារយោង

- **លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ**

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៣. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ

៤. ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

៥. ច្បាប់ភូមិបាល ឆ្នាំ២០០១

៦. ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៣៩ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ឆ្នាំ២០០៦

៧. អនុក្រឹត្យ លេខ ១២៩អនក្រ.បក ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ឆ្នាំ២០០៦

- **សៀវភៅពាក់ព័ន្ធ**

៨. សៀវភៅ នីតិនគរូបនីយកម្ម របស់លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា បង្រៀនក្នុងឆ្នាំសិក្សា ២០១៦-២០១៧

៩. សៀវភៅច្បាប់អចលនវត្ថុនៅកម្ពុជា រៀបរៀងដោយ East-West management Institute.Inc

- **វចនានុក្រម**

១០. វចនានុក្រមខ្មែររបស់សម្តេចសង្ឃ ជួន ណាត ឆ្នាំ២០១១

- **គេហទំព័រពាក់ព័ន្ធ**

១១. គេហទំព័ររបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (http://www.mlmupc.gov.kh)

១២. គេហទំព័ររបស់ហ្វេកប៊ុក (https://www.facebook.com)

១៣. គេហទំព័ររបស់វិទ្យាស្ថានអាឡឺម៉ង់សម្រាប់កិច្ចការសន្តិសុខ និងអន្តរជាតិ (https://www.swp-berlin.org)

១៤. គេហទំព័ររបស់កាសែតខេមបូឌាដេលី (http://www.cambodiadailykhmer.com)

១៥. គេហទំព័ររបស់កាសែតកម្ពុជាថ្មី (www.kampucheathmey.com)

១៦. គេហទំព័ររបស់កាសែតកោះសន្តិភាព (https://kohsantepheapdaily.com.kh)

១៧. គេហទំព័ររបស់កាសែតអាស៊ីសេរីសម្លេងអាមេរិកកាំង (http://www.rfa.org/khmer/news)

១៨. គេហទំព័ររបស់កាសែតអាស៊ីសេរីសម្លេងបារាំង (http://www.rfi.org/khmer/news)

១៩. គេហទំព័ររបស់កាសែតខ្មែរសារិកា (https://khmersahrika.com)

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ជំពូកទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

**ឧបសម្ព័ន្ធទី២៖** ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

**ឧបសម្ព័ន្ធទី៣៖** ព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៣៩ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ លេខ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យ លេខ១២៩ អនក្រ.បក ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ

**ឧបសម្ព័ន្ធទី៦៖** ទិដ្ឋភាពផ្សារកំពង់ជ្រៃ ខេត្តតាកែវ ក្នុងឆ្នាំ២០១៧ ក្រោយពីធ្វើអស្សាមិករណ៍

**ឧបសម្ព័ន្ធទី៧៖** គម្រោងសាងសង់ស្លាបខាងជើងស្ពានព្រែកក្ដាម នៅភូមិទួលងោក ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល

**ឧបសម្ព័ន្ធទី៨៖** ស្ថានីយ៍ប្រេងឥន្ធនៈមួយកន្លែង ស្ថិតក្នុងគម្រោងពង្រីកផ្លូវ និងសាងសង់ស្ពានអាកាសដែលធ្វើនៅសង្កាត់ចោមចៅ រាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី៩៖** កំណាត់ផ្លូវដែកមួយដែលលាតសន្ធឹងពីផ្លូវជាតិលេខ៥ កាត់តាមសង្កាត់មួយចំនួនក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

**ឧបសម្ព័ន្ធទី១០៖** ព្រះវិហារអាល់សីកាល (ព្រះវិហារអ៊ិស្លាម) មានទីតាំងនៅក្បែរតំបន់បឹងកក់

**ឧបសម្ព័ន្ធទី១១៖** គម្រោងអភិវឌ្ឍនៅអគារប៊ូឌីញ

# ឧបសម្ព័ន្ធទី១

## ជំពូកទី ៣
## អំពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤.- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌



Downloaded from http://www.khmerlaws.com

របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធ-ភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុស



Downloaded from http://www.khmerlaws.com

ច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណង ជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្ដាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្ដី ជាសមូហភាពក្ដី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្ដល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។



Downloaded from http://www.khmerlaws.com

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសម្រាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧.-**

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធស្របច្បាប់របស់ឯកជន ។



Downloaded from http://www.khmerlaws.com

# ឧបសម្ព័ន្ធទី ២

# ព្រះរាជក្រម

នស/រកម/០៤១០/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១០៨/០០១/២០១០ ធ.ធ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# អស្សាមិករណ៍

# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និង សំណងឱ្យបានសមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងជាអាទិ៍ :

- ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធម៌
- ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌
- បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ
- ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការធ្វើអស្សាមិករណ៍ដែលមានពាក់ព័ន្ធទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មិនគ្របដណ្តប់លើកិច្ចព្រមព្រៀង ឬ អនុស្សារណៈ ស្តីពីការគាំពារវិនិយោគ រវាងរាជរដ្ឋាភិបាល និង ប្រទេសជាដៃគូដែលមានចែងពីអស្សាមិករណ៍ទេ ។ ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងនេះទេ ឬ ក្នុងករណីដែលកិច្ចព្រមព្រៀង ឬ អនុស្សារណៈពុំមានចែងពីអស្សាមិករណ៍ គឺត្រូវស្ថិតនៅក្រោមអានុភាពនៃច្បាប់នេះ ។

**មាត្រា ៤.-**

ពាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានដូចតទៅ :

**អស្សាមិករណ៍** សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន ដីសំណង់ និង ដីណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និង យុត្តិធម៌ ។

**ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ** សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន កម្មសិទ្ធិករ ភោគី និង អ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដីដែលជាអ្នកទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍ ។

**ផលប្រយោជន៍សាធារណៈ ឬ ទូទៅ** សំដៅដល់ការប្រើប្រាស់ដី ឬ ទ្រព្យសម្បត្តិដោយសាធារណជនទូទៅ ឬ ដោយទីភ្នាក់ងារ ឬ ស្ថាប័នរដ្ឋ ឬ សាធារណៈ ។

**តម្រូវការនៃផលប្រយោជន៍ជាតិ** សំដៅដល់សកម្មភាព ឬ គម្រោងមានជាអាទិ៍ :

- ការសាងសង់ ស្តារ ថែទាំ ឬ ពង្រីក សំណង់ចាំបាច់ដល់កិច្ចការការពារជាតិ ឬ ការងារសន្តិសុខ

- ការកាន់កាប់ដី ឬ ទ្រព្យសម្បត្តិ ដើម្បីអនុវត្តជាក់ស្តែងនយោបាយការពារបូរណភាពទឹកដី ។

**អ្នកអនុវត្តគម្រោង** សំដៅដល់រដ្ឋ សហគ្រាស និង គ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬ វិនិយោគិន ។

**អតិថិ:** សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និងសិទ្ធិប្រើប្រាស់លើអចលនវត្ថុ ពីម្ចាស់អចលនវត្ថុ ។

**បុគ្គលដែលធ្វើការរារាំង** សំដៅដល់ រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនទាំងឡាយណាដែលជាមេក្លោង អ្នកសមគំនិត អ្នកញុះញង់ ដែលធ្វើសកម្មភាពដោយផ្ទាល់ ឬ ដោយប្រយោល ដោយគំនិតទុច្ចរិតក្នុងគោលដៅធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តស្របច្បាប់នៃគម្រោងអស្សាមិករណ៍ ។

**មាត្រា ៥.-**

គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ មានជាអាទិ៍ :

ក- ការសាងសង់ ឬ ពង្រីកផ្លូវអាយស្ម័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និង ឧបករណ៍ ។

ខ- ការសាងសង់ ឬ ពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និង ខ្សែ សម្រាប់ការបញ្ជូន និង ចែកចាយថាមពលអគ្គិសនី ។

គ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ប្រព័ន្ធព័ត៌មានវិទ្យា ។

ឃ- ការសាងសង់ ឬ ពង្រីកផ្លូវ ផ្លាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និង ទីលានសាធារណៈ ។

ង- ការសាងសង់ ឬ ពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធ លូទឹកកខ្វក់ និង កន្លែងបម្រើសេវាសាធារណៈផ្សេងទៀត ។

ច- ការសាងសង់ ឬ ពង្រីកអគារ សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និង កីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ ។

ឆ- ការសាងសង់ ឬ ពង្រីកកន្លែងចម្រាញ់ និង កន្លែងប្រព្រឹត្តកម្ម សំណង់ ឧបករណ៍ សម្រាប់ការការពារធម្មជាតិ និង បរិស្ថាន ។

ជ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ស្រាវជ្រាវ និង សម្រាប់ ការធ្វើអាជីវកម្មរ៉ែ និង ធនធានធម្មជាតិផ្សេងទៀត ។

ឈ- ការសាងសង់ ឬ ពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្រឬមប្រេង និង បណ្តាញដទៃទៀត ។

ញ- ការសាងសង់ ឬ ពង្រីកអគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញ យ៉ាងធ្ងន់ធ្ងរពីធម្មជាតិមាន រញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ និង គ្រោះរាំងស្ងួតជាដើម និង ការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ ។

ដ- ការសាងសង់ ឬ ពង្រីកអគារសម្រាប់ការការពារ និង ការគាំពារប្រជាជន ។

ឋ- ការសាងសង់ ឬ ពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន ។

ឌ- ការកសាង ពង្រីក ឬ ការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការធានាសន្តិសុខ ។

ឍ- ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភ័ណ្ឌវប្បធម៌បុរាណវិទ្យា ឬ ការពារបរិស្ថាន ។

ណ- ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី ២

## គោលការណ៍ទូទៅ

**មាត្រា ៦.-**

អស្សាមិករណ៍ អាចធ្វើលើអចលនវត្ថុមួយផ្នែក ឬទាំងស្រុង ឬ លើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ ។

**មាត្រា ៧.-**

មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ។

អស្សាមិករណ៍អាចអនុវត្តទៅបាន លុះត្រាតែយកទៅអនុវត្តគម្រោង ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ។

**មាត្រា ៨.-**

រដ្ឋត្រូវតែទទួលទិញយកនូវចំណែកនៃអចលនវត្ថុ ដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយថ្លៃសមរម្យ និង យុត្តិធម៌ តាមសំណើរបស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិដែលពុំអាចរស់នៅក្បែរគម្រោងបាន ឬ ពុំអាចសាងសង់លំនៅឋានបាន ឬ ពុំអាចប្រកបអាជីវកម្មអ្វីផ្សេងទៀតបាន ។

**មាត្រា ៩.-**

អចលនវត្ថុដែលត្រូវបានដកហូតនេះ ត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅដែលបានគ្រោងទុកនៅក្នុងប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដើម្បីប្រយោជន៍សាធារណៈ ឬ តម្រូវការនៃផលប្រយោជន៍ជាតិប៉ុណ្ណោះ និង មិនអាចឱ្យទុកនៅចោលទំនេរដោយគ្មានហេតុផលសមស្រប ឬ ផ្ទេរឱ្យតតិយជនណាម្នាក់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជន

អចលនវត្ថុដែលនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្តល់អាទិភាពលក់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ តាមអត្រាតម្លៃនៃការទូទាត់សំណង ។ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនព្រមទទួលយកអចលនវត្ថុដែលសល់ពីតម្រូវការប្រើប្រាស់វិញទេ ត្រូវរក្សាទុកអចលនវត្ថុនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ១០.-**

ក្នុងករណីពិសេស និង បន្ទាន់ ដែលសុវត្ថិភាពសាធារណៈតម្រូវ ដូចជា ប្រយុទ្ធប្រឆាំងគ្រោះអគ្គិភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬ ការវាយប្រហារដោយភេរវកម្ម និង ស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្ន ដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូតនេះ ។

ក្នុងករណីបន្ទាន់ និង ចាំបាច់ដែលផលប្រយោជន៍ជាតិតម្រូវ រាជរដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិក្នុងការធ្វើអស្សាមិករណ៍ ដោយមិនចាំបាច់រៀបចំធ្វើការពិគ្រោះយោបល់តាមនីតិវិធី ដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់នេះទេ ។

**មាត្រា ១១.-**

មុននឹងដំណើរការការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឱ្យគ្រប់ចំនួន និង ទាន់ពេលវេលាជូនគណៈកម្មាធិការអស្សាមិករណ៍ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលរងនូវផលប៉ះពាល់ដោយសារអស្សាមិករណ៍ ។

## ជំពូកទី ៣
## យន្តការអស្សាមិករណ៍

**មាត្រា ១២.-**

គណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៣.-**

អនុគណៈកម្មាធិការអស្សាមិករណ៍ ជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និង ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង មានតំណាងមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១៤.-**

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង មានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី ៤
## នីតិវិធីនៃអស្សាមិករណ៍
### ផ្នែកទី ១
### នីតិវិធីមុនអស្សាមិករណ៍

**មាត្រា ១៥.-**

អស្សាមិករណ៍ ត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និង មានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួង ស្ថាប័នសាមី ។

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និង សម្រេច ។

**មាត្រា ១៦.-**

មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឱ្យបានលម្អិតចំពោះរាល់សិទ្ធិរបស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ លើអចលនវត្ថុ និង ទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណង ព្រមទាំងត្រូវកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ ។

ក្នុងការធ្វើការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងភូមិ ឬ សហគមន៍ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ពត៌មាន ជាក់លាក់ ច្បាស់លាស់ និង ទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

ដើម្បីកំណត់ពេលវេលាដកហូត ឬ ទឹកន្លែងដែលផ្តល់ថ្មី ឬ សំណង គណៈកម្មាធិការអស្សាមិករណ៍ ត្រូវសាកសួរគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីបញ្ហាអចលនវត្ថុ ដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានាដាក់ជូន និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ១៧.-**

ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ត្រូវចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលក្នុងនោះត្រូវជម្រាបដល់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិឱ្យបានដឹងអំពីអចលនវត្ថុដែលជាកម្មវត្ថុនៃការដកហូតនោះ និង ត្រូវចែងអំពីគោលបំណង នៃការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិលើអចលនវត្ថុឱ្យបានច្បាស់លាស់ ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

ក- កំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំង [illegible] និង រយៈពេលសម្រាប់អនុវត្តគម្រោង និង អាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិដើម្បីធ្វើការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិ ឬ ទ្រព្យសម្បត្តិឯកជន

ខ- កំណត់អំពីសំណងសមរម្យ និង យុត្តិធម៌

គ- កំណត់រយៈពេលនៃបណ្តឹងតវ៉ា

ឃ- ផ្ញើសេចក្តីប្រកាសទៅដល់គ្រប់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិដោយភ្ជាប់នូវលិខិតថតចម្លងនៃច្បាប់នេះ

ង- ដាក់ស្លាកសម្គាល់ថា អចលនវត្ថុនេះជាកម្មវត្ថុត្រូវដកហូតសម្រាប់បម្រើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

ច- ផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ

ឆ- បិទផ្សាយសេចក្តីប្រកាសនៅសាលាឃុំ សង្កាត់ ពាក់ព័ន្ធនឹងទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ហើយសេចក្តីប្រកាសនេះត្រូវផ្សព្វផ្សាយជូនដល់ប្រជាជនដែលមានអចលនវត្ថុពាក់ព័ន្ធដោយមេភូមិ ។

**មាត្រា ១៨.-**

បន្ទាប់ពីទទួលបាននូវសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិអាចធ្វើបណ្តឹងសុំឱ្យមានការអង្កេត ដើម្បីឱ្យដឹងថាជាតម្រូវការមួយចាំបាច់ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិពិតប្រាកដមែន ឬ ក៏អាចបង្វែរទីតាំងគម្រោងទៅកន្លែងណាផ្សេងវិញបាន ។ បណ្តឹងនេះអាចធ្វើឡើងតាមរយៈមេធាវី ឬ តំណាងរបស់ខ្លួន ។

បណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបានទទួលសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ជូនចំពោះគណៈ-កម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។ ខ្លឹមសារសំខាន់ៗនៃបណ្តឹងមាន ជាអាទិ៍ :

- ឈ្មោះម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាសយដ្ឋាន និង លេខទូរស័ព្ទ
- មូលហេតុនៃការធ្វើបណ្តឹង
- ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ
- ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិនៅលើដីដែលត្រូវ

[illegible]

ប៉ុន្តែម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនអាចធ្វើពាក្យបណ្តឹងតវ៉ាសុំឱ្យមានធ្វើការអង្កេតបានទេ ចំពោះតម្រូវការសម្រាប់កិច្ចអភិវឌ្ឍផ្លូវជាតិធំៗ ស្ពាន ផ្លូវរទេះភ្លើង ការតភ្ជាប់ ការចែកចាយបណ្តាញទឹក ភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកកខ្វក់ ខ្សែបណ្តាញ ឬ លូមេបង្ហូរទឹក ប្រព័ន្ធធារាសាស្ត្រ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានា និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

## ផ្នែកទី ២
## កិច្ចដំណើរការអស្សាមិករណ៍

**មាត្រា ១៩.-**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបាន លុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធម៌ តាមគោលការណ៍ និង នីតិវិធីនៃការទូទាត់សំណងដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ៤ នៃច្បាប់នេះ ។

ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី ។ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលបានទទួលប្រាក់សំណងតាមការកំណត់របស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់ និង ការដោះស្រាយទំនាស់ដូចបានកំណត់ក្នុងមាត្រា ៣៤ ជំពូកទី ៦ នៃច្បាប់នេះ ។

**មាត្រា ២០.-**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ ។ សេចក្តីសម្រេចអស្សាមិករណ៍ ត្រូវកំណត់ជាអាទិ៍ :

- កម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវដកហូត
- សំណងដែលត្រូវទូទាត់
- កាលបរិច្ឆេទដែលតម្រូវឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិធ្វើការរុះរើ ចាកចេញពីទីតាំង និង ធ្វើការប្រគល់អចលនវត្ថុ ជូនគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២១.-**

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជូនដំណឹងអំពីសេចក្តីសម្រេចអស្សាមិករណ៍ និង ត្រូវផ្តល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មុននឹងធ្វើអស្សាមិករណ៍ ។

## ផ្នែកទី ៣
## ការទូទាត់សំណងនៃអស្សាមិករណ៍

**មាត្រា ២២.-**

ប្រាក់សំណងដែលត្រូវផ្តល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៣.-**

ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និង យុត្តិធម៌ ។

**មាត្រា ២៤.-**

សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួសទៅតាមភាពជាក់ស្តែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៍ ។

បែបបទ និង នីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២៥.-**

ប្រាក់សំណងត្រូវគិតតាមតម្លៃសំណងសរុប ដកចំនួនទឹកប្រាក់បន្ទុកពន្ធប្រថាប់ត្រា និង/ ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនរដ្ឋ ហើយគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះចូលថវិកាជាតិ តាមនីតិវិធីជាធរមាន ។

**មាត្រា ២៦.-**

ប្រាក់សំណងចំពោះកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ មិនត្រូវបានគិតដល់ការប្រែប្រួលនៃតម្លៃដែលកើតមានឡើង ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍នោះឡើយ ដោយការប្រែប្រួលទាំងនោះអាចពាក់ព័ន្ធដល់ការផ្លាស់ប្តូរវិធានការបម្រុងផ្ទៃដីទុកដែលមានក្នុងផែនការនគរូបនីយកម្ម ដែលកំណត់តំបន់ប្រើប្រាស់ដីធ្លី ឬ ផែនការប្រើប្រាស់ដីធ្លីដែលបានអនុម័តត្រឹមត្រូវ ឬ ដោយការប្រែប្រួលនោះបណ្តាលមកពីសេចក្តីប្រកាស ស្តីពីគម្រោងអស្សាមិករណ៍ ។

**មាត្រា ២៧.-**

បន្ទាប់ពីទទួលបានប្រាក់សំណងគ្រប់ចំនួនរួចហើយ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការថែរក្សា ស្នាក់អាស្រ័យ កាន់កាប់ និង ទទួលផលដែលលើសិទ្ធិ និង អចលនវត្ថុ រហូតដល់មានការទទួលយកអចលនវត្ថុទាំងនោះ ដោយគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៨.-**

គណៈកម្មាធិការអស្សាមិករណ៍អាចទទួលយកអចលនវត្ថុ ឬ សិទ្ធិលើអចលនវត្ថុនោះក្រោយពី :

- បានអនុវត្តតាមនីតិវិធី និង លក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី ១ និង ផ្នែកទី ២ ជំពូកទី ៥ នៃច្បាប់នេះ

- ការផ្តល់ប្រាក់សំណងត្រូវបានអនុវត្តតាមគោលការណ៍ និង នីតិវិធីដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី ៤ នៃច្បាប់នេះ ។

**មាត្រា ២៩.-**

ភតិកៈអចលនវត្ថុដែលមានកិច្ចសន្យាត្រឹមត្រូវ ត្រូវទទួលបានទូវសំណងសម្រាប់ការវិនាសនានា ពាក់ព័ន្ធនឹងការដកហូតជាអាទិ៍ ការរុះរើសំណង់ សម្ភារៈ ការដឹកជញ្ជូនទៅកាន់ទីតាំងថ្មី ។

ចំពោះភតិកៈអចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបានទូវសំណងលើផលប៉ះពាល់ដល់អាជីវកម្មនិងការឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃដើមទុនដែលបានចំណាយជាក់ស្តែង សម្រាប់សកម្មភាពនៃការប្រកបរបរអាជីវកម្មនោះ ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ចំពោះការដកហូតយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិទទួលបានសំណងឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

## ជំពូកទី ៥
## អន្តរកាលនៃការកាន់កាប់ និង គ្រប់គ្រងអចលនវត្ថុ

**មាត្រា ៣០.-**

ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិពុំអាចលក់ ឬ ផ្ទេរអចលនវត្ថុនោះឱ្យអ្នកដទៃបានឡើយ ។ លិខិតឯកសារនានា និង នីតិវិធីទាំងអស់ដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ត្រូវចាត់ទុកជាមោឃៈ ។

ចំពោះការប្រើប្រាស់ដី ឬ អចលនវត្ថុពាក់ព័ន្ធ ត្រូវរក្សាលក្ខណៈ និង ទំហំប្រើប្រាស់ដូចមាននៅពេលចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ហើយមិនត្រូវសាងសង់សំណង់នៅលើដីនោះថែមទៀតឡើយ ។ សកម្មភាពណាដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មិនត្រូវមានសិទ្ធិទទួលបានសំណងលើការសាងសង់សំណង់បន្ថែមនោះឡើយ ។

**មាត្រា ៣១.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចកាន់កាប់អចលនវត្ថុទាំងនោះបានត្រឹមរយៈពេល ១ ( មួយ ) ខែ បន្ទាប់ពីគណៈកម្មាធិការអស្សាមិករណ៍បានទូទាត់សំណងគ្រប់ចំនួនស្របតាមនីតិវិធី ដូចមានចែងនៅក្នុងជំពូកទី ៤ នៃច្បាប់នេះ លើកលែងតែមានការព្រមព្រៀង ឬ មានការអនុញ្ញាតផ្ទុយពីនេះ ។

ក្នុងករណីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិពុំព្រមចាកចេញពីទីកន្លែងនោះ គណៈ-កម្មាធិការអស្សាមិករណ៍អាចស្នើសុំទៅស្ថាប័នមានសមត្ថកិច្ច ឬ អាជ្ញាធរសាធារណៈ ដើម្បីចាត់វិធានការ តម្រូវឱ្យជននោះចាកចេញពីទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ។

## ជំពូកទី ៦

## ការដោះស្រាយទំនាស់

**មាត្រា ៣២.-**

គណៈកម្មាធិការអស្សាមិករណ៍ និង គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា មានសមត្ថកិច្ចទទួលពិនិត្យ និង ដោះស្រាយបណ្តឹងតវ៉ា ។

**មាត្រា ៣៣.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ។

**មាត្រា ៣៤.-**

ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចប្តឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និង យុត្តិធម៌ ។

[illegible]បទ និង នីតិវិធីប្តឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៣៦.-**

បុគ្គលណាដែលធ្វើការរារាំងដល់ការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ដោយគំនិតទុច្ចរិត ធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ខែ ដល់ ១ ( មួយ ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ ( មួយសែន ) រៀល ដល់ ២.០០០.០០០ ( ពីរលាន ) រៀល ។

**មាត្រា ៣៧.-**

បុគ្គលណាដែលបានកាន់កាប់ ប្រើប្រាស់ដោយវិលោភបំពានលើទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៩.–

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១០

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំរាប់បន្ទាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

ពរ/ល. ១០០២/. ១៩៩

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្ដេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខៈ ១៨៥ ច.ល

[illegible]ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មីនា ឆ្នាំ២០១០

[illegible]រដ្ឋាភិបាល

[illegible]

# ឧបសម្ព័ន្ធទី ៣

នស/រកត/០៨០៦/៣៣៩

# ព្រះរាជក្រឹត្យ

# ស្តីពី

# គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

# យើង

# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/ ០២៩៨/ ០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៦

# ត្រាស់បង្គាប់

**មាត្រា ១.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់គោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ។

**មាត្រា ២.-**

អនុបយោគ គឺជាប្រតិបត្តិការនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ លើទ្រព្យសម្បត្តិរបស់រដ្ឋ ដែលនាំឱ្យមានការផ្លាស់ប្តូរឋានៈ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**មាត្រា ៣.-**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ ត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ÷

- ទ្រព្យសម្បត្តិនោះ លែងជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬ
- ទ្រព្យសម្បត្តិនោះ បាត់បង់លក្ខណៈសម្បត្តិពេញលេញរបស់ខ្លួនក្នុងការបម្រើប្រយោជន៍សាធារណៈ ឬ
- ទ្រព្យសម្បត្តិនោះ លែងជាការប្រើប្រាស់ដោយផ្ទាល់ ដោយសាធារណជន។

**មាត្រា ៤.-**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចធ្វើទៅបានតែចំពោះទ្រព្យសម្បត្តិទាំងឡាយណា ដែលបានចុះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋរួចជាស្រេច។

**មាត្រា ៥.-**

រាជរដ្ឋាភិបាល សម្រេចធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដោយអនុក្រឹត្យ។

វិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។៥

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខ : ៣២១ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជីនកេន**

៣រល-០៦០៨.៣៦០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៦*

# ឧបសម្ព័ន្ធទី ៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ , នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .–**

អនុក្រឹត្យនេះមានគោលបំណង ÷

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយ ក្រសួងបរិស្ថានមុន ដាក់ជូនរាជរដ្ឋាភិបាលសំរេច
- កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុង ដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន
- បំផុសឱ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រម ទាំង ទទួលយកមតិ យោបល មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគំរោង ។

**មាត្រា ២ .–**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគំរោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសំរេចដោយរាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា ៣ .–**

ក្រសួងបរិស្ថាន មានភារៈកិច្ច ÷

ក.ពិនិត្យ និងវាយតំលៃលើ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ.

ខ.តាមដាន ឃ្លាំមើល និងចាត់វិធានការ ឱ្យម្ចាស់គំរោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច ។

**មាត្រា ៤ .–**

ស្ថាប័ន និងក្រសួង ដែលមានសិទ្ធិអនុម័តលើគំរោង មានភារៈកិច្ច ពិនិត្យ និងសំរេចលើគំរោង ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៥ .–**

អាជ្ញាធរខេត្ត-ក្រុង ដែលមានសិទ្ធិអនុម័តលើគំរោង ខេត្ត-ក្រុង មានភារៈកិច្ច ÷

- បញ្ជូននូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគំរោងដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ទៅមន្ទីរបរិស្ថានខេត្ត-ក្រុង
- ពិនិត្យ និងសំរេចលើគំរោង បន្ទាប់ពីបានពិចារណាលើយោបល់របស់មន្ទីរ បរិស្ថានថ្នាក់ខេត្ត-ក្រុង ដែល ក្រសួងបរិស្ថានបានប្រគល់សិទ្ធជូន ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៣
## តម្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងស្នើសុំ

**មាត្រា ៦ .–**

ម្ចាស់គំរោងត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគំរោងដែលតម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧ .–**

ម្ចាស់គំរោង ត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍សិក្សាបុរេលិទ្ធភាពទៅក្រសួងបរិស្ថាន ។

**មាត្រា ៨ .–**

ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគំរោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខមាលភាពសាធារណៈ ។

**មាត្រា ៩ .–**

ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ ទៅមន្ទីរបរិស្ថាន ខេត្ត-ក្រុង ចំពោះ គំរោងថ្នាក់ ខេត្ត-ក្រុង ។

**មាត្រា ១០ .–**

គោលការណ៍ណែនាំ ស្តីពីការធ្វើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១១ .–**

ម្ចាស់គំរោងត្រូវបង់ថ្លៃសេវាការងារ សំរាប់ការពិនិត្យលើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការតាមដាន ឃ្លាំមើល ការអនុវត្តន៍គំរោង ។ តំលៃសេវាការងារនេះត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិកាជាតិ ។

**មាត្រា ១២ .–**

ម្ចាស់គំរោងត្រូវបង់វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន សំរាប់កិច្ចការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា ១៩ ជំពូកទី៨ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធាន ធម្មជាតិ ។

**មាត្រា ១៣ .–**

ពាក្យសុំត្រូវបំពេញដោយម្ចាស់គំរោង និងត្រូវផ្តល់ជូនដោយក្រសួងបរិស្ថាន ចំពោះគំរោងថ្នាក់ក្រសួង-ស្ថាប័ន និងត្រូវផ្តល់ជូនដោយមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះគំរោងថ្នាក់ ខេត្ត-ក្រុង ។

## ជំពូកទី ៤

## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងស្នើសុំ

**មាត្រា ១៤ .–**

ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៧ ទៅក្រសួងបរិស្ថាន និងផ្តល់លិខិតចំលង ទៅស្ថាប័នអនុម័តគំរោង ។

**មាត្រា ១៥ .-**

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូន យោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គំរោង ។

**មាត្រា ១៦ .-**

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឱ្យមានរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៨ ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគំរោង ។

**មាត្រា ១៧ .-**

ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូន យោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ពីម្ចាស់គំរោង ។

**មាត្រា ១៨ .-**

ក្នុងករណី ក្រសួងបរិស្ថានខកខានមិនបានបញ្ជូនយោបល់ និងសំណើដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា១៧ នោះ ស្ថាប័នអនុម័តគំរោងអាចកំណត់ថា គំរោងនោះត្រូវបានបំពេញតាម តម្រូវការនៃអនុក្រឹត្យនេះ ។

**មាត្រា ១៩ .-**

ក្នុងសមត្ថកិច្ច ជាស្ថាប័នអនុម័តគំរោងផង និងជាម្ចាស់គំរោងផងនោះ ម្ចាស់គំរោងត្រូវមានភារៈកិច្ចអនុវត្តតាមកិច្ចដំណើរការ ដូចមានចែងក្នុងជំពូកទី៣ និងជំពូកទី៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០ .–**

មុនចាប់ដំណើរការអនុវត្តគំរោង ម្ចាស់គំរោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថានលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

## ជំពូកទី ៥
## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតំលៃហេតុប៉ះពាល់បរិស្ថាន ចំពោះសកម្មភាពមានស្រាប់

**មាត្រា ២១ .–**

ក្នុងរយៈពេលយ៉ាងយូរ ០១ ឆ្នាំ បន្ទាប់ពី អនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកក្រសួងបរិស្ថាន ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការ ដែលបានទទួលការអនុម័តពីថ្នាក់ក្រសួង-ស្ថាប័ន ។

**មាត្រា ២២ .–**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី ៣ និងជំពូកទី៤ នៃអនុក្រឹត្យនេះ ក្នុងករណីដែលក្រសួងបរិស្ថាន បានពិនិត្យឃើញថាសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ តម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា ២៣ .–**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃ ដែលក្រសួងបរិស្ថានបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៤ .–**

ក្នុងរយៈពេលយ៉ាងយូរ ០២ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការដែលបានទទួលការអនុម័តពីថ្នាក់ ខេត្ត-ក្រុង ។

**មាត្រា ២៥ .–**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី ៣ និងជំពូកទី ៤ នៃអនុក្រឹត្យនេះ ក្នុងករណីដែលមន្ទីរបរិស្ថានខេត្ត-ក្រុងពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការតម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា ២៦ .–**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃដែល មន្ទីរបរិស្ថានខេត្ត-ក្រុងបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ ។

## ជំពូកទី៦
## លក្ខខណ្ឌ នៃការអនុម័តគំរោង

**មាត្រា ២៧ .–**

ស្ថាប័នអនុម័តគំរោង ត្រូវណែនាំម្ចាស់គំរោង ឬម្ចាស់កម្មសិទ្ធ ឱ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគំរោង ដូចបានរៀបរាប់ក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តដោយក្រសួងបរិស្ថាន ។

**មាត្រា ២៨ .–**

ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធចេញបញ្ជាឱ្យផ្អាកសកម្មភាព ចំពោះម្ចាស់គំរោង

ឬម្ចាស់កម្មសិទ្ធណា ដែលពុំបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃតំរោង ដូចបានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានឯកភាពរួចហើយ ។

## ជំពូកទី ៧
## ទោសប្បញ្ញត្តិ

**មាត្រា ២៩ .-**

ម្ចាស់តំរោង ឬម្ចាស់កម្មសិទ្ធដែលខកខានមិនបានផ្តល់ ឬបកស្រាយខុសនូវពតិមាន ឬមិនបានអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នានៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយ នៃអនុក្រឹត្យនេះត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២០/២១/ ២២/២៣ និងមាត្រា ២៥ ជំពូកទី៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣០ .-**

កំណត់ហេតុ និងការធ្វើបណ្តឹងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយ នៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៣១ .-**

មន្ត្រីបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា របស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តិបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោស ផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៣ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារៈកិច្ចរៀង១ខ្លួន ។

**មាត្រា ៣៤ .–**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

**<u>ចំលងជូន</u> :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៣៣
- កាលប្បវត្តិ - ឯកសារ

តារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៧២.អនក្រ.បក ចុះថ្ងៃទី១១..ខែសីហាឆ្នាំ១៩៩៩

ចំណាត់ថ្នាក់គំរូងឱ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

| ល.រ | ប្រភេទអាជីវកម្ម | ទំហំ |
|---|---|---|
| **១** | **វិស័យឧស្សាហកម្ម** | |
| **១.១** | **ផ្នែក ស្បៀង, ម្ហូបអាហារ គេសជ្ជៈ និង ថ្នាំជក់** | |
| ១.១.១ | មូលដ្ឋានកែច្នៃម្ហូបអាហារ និងគ្រឿងកំប៉ុង | ≥ ៥០០ តោន/ឆ្នាំ |
| ១.១.២ | មូលដ្ឋានផលិតភេសជ្ជៈ - ទឹកផ្លែឈើគ្រប់ប្រភេទ | ≥ ១.៥០០ លីត្រ/ថ្ងៃ |
| ១.១.៣ | មូលដ្ឋានផលិតដំណាប់ផ្លែឈើ | ≥ ៥០០ តោន/ឆ្នាំ |
| ១.១.៤ | មូលដ្ឋានផលិតទឹកក្រូច | គ្រប់ទំហំ |
| ១.១.៥ | មូលដ្ឋានផលិតស្រា | គ្រប់ទំហំ |
| ១.១.៦ | មូលដ្ឋានផលិតស្រាបៀរ - អាល់កុល | គ្រប់ទំហំ |
| ១.១.៧ | មូលដ្ឋានផលិតទឹកស្អាត | ≥ ១០.០០០ នាក់ប្រើប្រាស់ |
| ១.១.៨ | មូលដ្ឋានផលិតបារី | ≥ ១០.០០០ កញ្ចប់/ថ្ងៃ |
| ១.១.៩ | មូលដ្ឋានផលិត កែច្នៃសន្លឹកថ្នាំជក់ | ≥ ៣៥០ តោន/ឆ្នាំ |
| ១.១.១០ | មូលដ្ឋានផលិតស្ករស | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១.១១ | មូលដ្ឋានកិនស្រូវ និងគ្រាប់ធញ្ញជាតិ | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១.១២ | មូលដ្ឋានផលិតទឹកត្រី - ស៊ីអ៊ីវ - សៀង - ម្ទេស - ប៉េងប៉ោះ | ≥ ៥០០.០០០ លីត្រ/ឆ្នាំ |
| **១.២** | **ផ្នែកវាយនភ័ណ្ឌ, សំលៀកបំពាក់, និង ផលិតផលស្បែក** | |
| ១.២.១ | រោងចក្រតម្បាញ - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.២ | រោងចក្រកាត់ដេរ - បោកគក់ - បោះពុម្ព - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.៣ | រោងចក្រសំលាប់ស្បែក - កែច្នៃស្បែក - ធ្វើការស្បែកគោក្របី | គ្រប់ទំហំ |
| ១.២.៤ | រោងចក្រផលិតអេប៉ុង - កៅស៊ូមូស | គ្រប់ទំហំ |
| **១.៣** | **ផ្នែកផលិតផលពីឈើ** | |
| ១.៣.១ | រោងចក្រក្ការបន្ទះ | ≥ ១០០.០០០ ម៣/ឆ្នាំ ឈើមូល |

| | | |
|---|---|---|
| ១.៣.២ | មូលដ្ឋានផលិតគ្រឿងសង្ហារឹម | ≥ ១.០០០ម៉ែត្រ/ឆ្នាំ ឈើមូល |
| ១.៣.៣ | រោងចក្រអារឈើ | ≥ ៥០.០០០ម៉ែត្រ/ឆ្នាំឈើមូល |
| **១.៤** | **ផ្នែកផលិតក្រដាស** | |
| ១.៤.១ | រោងចក្រផលិតក្រដាស | គ្រប់ទំហំ |
| ១.៤.២ | រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស | គ្រប់ទំហំ |
| **១.៥** | **ផ្នែកគីមី - ផលិតផលពីកៅស៊ូ និងប្លាស្ទិក** | |
| ១.៥.១ | រោងចក្រប្លាស្ទិក | គ្រប់ទំហំ |
| ១.៥.២ | រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ | ≥ ៥០០ តោន/ឆ្នាំ |
| ១.៥.៣ | រោងចក្រកៅស៊ូក្រែប | ≥ ១.០០០ តោន/ឆ្នាំ |
| ១.៥.៤ | រោងចក្រផលិតអាគុយ និងថ្មពិល | គ្រប់ទំហំ |
| ១.៥.៥ | រោងចក្រគីមី | គ្រប់ទំហំ |
| ១.៥.៦ | រោងចក្រផលិតជីគីមី | ≥ ១០.០០០ តោន/ឆ្នាំ |
| ១.៥.៧ | រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត | គ្រប់ទំហំ |
| ១.៥.៨ | រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៥.៩ | រោងចក្រគីមីប្រេងកាត | គ្រប់ទំហំ |
| ១.៥.១០ | រោងចក្រផលិតម្សៅសាប៊ូ - សាប៊ូដុំ - សាប៊ូទឹក | គ្រប់ទំហំ |
| **១.៦** | **ផ្នែកផលិតផលពីរ៉ែ មិនមែនជាលោហៈ** | |
| ១.៦.១ | រោងចក្រស៊ីម៉ង់ត៍ | គ្រប់ទំហំ |
| ១.៦.២ | រោងចក្រចំរាញ់ប្រេងកាត | គ្រប់ទំហំ |
| ១.៦.៣ | រោងចក្រផលិតឧស្ម័ន | គ្រប់ទំហំ |
| ១.៦.៤ | សំណង់បង្ហូរប្រេង និងឧស្ម័ន | ≥ ២ គ.ម |
| ១.៦.៥ | កន្លែងស្តុកប្រេងឥន្ធនៈសំរាប់ចែកចាយ | ≥ ១.០០០.០០០ លីត្រ |
| ១.៦.៦ | ស្ថានីយប្រេងឥន្ធនៈ | ≥ ២០.០០០ លីត្រ |
| ១.៦.៧ | ការធ្វើអាជីវកម្មរ៉ែ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១.៦.៨ | រោងចក្រផលិតកែវ - ឋបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៦.៩ | មូលដ្ឋានផលិតឥដ្ឋក្បឿង | ≥ ១៥០.០០០ ដុំ/ខែ |
| ១.៦.១០ | មូលដ្ឋានផលិតឥដ្ឋក្រាល - ឥដ្ឋការ៉ូ | ≥ ៩០.០០០ ដុំ/ខែ |
| ១.៦.១១ | រោងចក្រផលិតថ្មស្អិត | គ្រប់ទំហំ |
| ១.៦.១២ | មូលដ្ឋានផលិតគ្រឿងសំណង់បេតុង | ≥ ៩០០ តោន/ខែ |
| ១.៦.១៣ | រោងចក្រផលិតខ្លាញ់គោ - ប្រេងម៉ាស៊ីន | គ្រប់ទំហំ |
| ១.៦.១៤ | ការសិក្សាស្រាវជ្រាវអាជីវកម្មរ៉ែប្រេងកាត (ការខួងសាកល្បង , ការធ្វើឲ្យរញ្ជួយដី ) | គ្រប់ទំហំ |
| **១.៧** | **ផ្នែកឧស្សាហកម្មលោហៈ មូលដ្ឋាន** | |
| ១.៧.១ | រោងចក្រផលិតគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.២ | រោងចក្រតំឡើងគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.៣ | សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា | គ្រប់ទំហំ |
| **១.៨** | **ផ្នែកឧស្សាហកម្មកែច្នៃលោហៈ** | |
| ១.៨.១ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ - ដែកគោល - លួសបន្លា - សំណាញ់ | ≥ ៣០០ តោន/ខែ |
| ១.៨.២ | រោងចក្រស្លដែក - ដែកថែប - អាលុយមីនីញ៉ូម | គ្រប់ទំហំ |
| ១.៨.៣ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| **១.៩** | **ផ្នែកឧស្សាហកម្មផ្សេងៗ** | |
| ១.៩.១ | មូលដ្ឋានកែច្នៃសំណល់ - ដុតសំណល់ | គ្រប់ទំហំ |
| ១.៩.២ | មូលដ្ឋានសំអាតទឹកសំអុយ | គ្រប់ទំហំ |
| ១.៩.៣ | រោងចក្រអគ្គិសនី | ≥ ៥ MW |
| ១.៩.៤ | រោងចក្រវារីអគ្គិសនី | ≥ ១ MW |
| ១.៩.៥ | រោងចក្រផលិតសំភ្លី | ≥ ១៥ តោន/ខែ |
| ១.៩.៦ | រោងចក្រផលិតចំណីសត្វ | ≥ ១០.០០០ [illegible] |

| | | |
|---|---|---|
| ២ | **វិស័យកសិកម្ម** | |
| ២.១ | ព្រៃសម្បទាន | ≥ ១០.០០០ ហិចតា |
| ២.២ | អាជីវកម្មព្រៃកប់ | ≥ ៥០០ ហិចតា |
| ២.៣ | ផ្ទៃដីដែលមានព្រៃឈើ | ≥ ៥០០ ហ.ត |
| ២.៤ | ផ្ទៃដីដំណាំកសិកម្ម - ឧស្សាហកម្ម | ≥ ១០.០០០ ហ.ត |
| ២.៥ | ផ្ទៃដីលិចទឹក និងដីតំបន់ឆ្នេរ | គ្រប់ទំហំ |
| ២.៦ | ប្រព័ន្ធស្រោចស្រព | ≥ ៥.០០០ ហ.ត |
| ២.៧ | ប្រព័ន្ធដោះទឹក | ≥ ៥.០០០ ហ.ត |
| ២.៨ | ដែននេសាទ | គ្រប់ទំហំ |
| ៣ | **វិស័យទេសចរណ៍** | |
| ៣.១ | តំបន់ទេសចរណ៍ | ≥ ៥០ ហ.ត |
| ៣.២ | ទីលានវាយកូនគោល | ≥ ១៨ រន្ធ |
| ៤ | **ហេដ្ឋារចនាសម្ព័ន្ធ** | |
| ៤.១ | ការអភិវឌ្ឍន៍ទីក្រុង | គ្រប់ទំហំ |
| ៤.២ | តំបន់ឧស្សាហកម្ម | គ្រប់ទំហំ |
| ៤.៣ | សំណង់ស្ពានថ្នល់ | ទ្រទំងន់ ≥ ៣០ តោន |
| ៤.៤ | សំណង់អាគារ | កំពស់ ≥ ១២ ម. ឬ ក្រឡាផ្ទៃ ៨.០០០ ម$^2$ |
| ៤.៥ | ភោជនីយដ្ឋាន | ≥ ៥០០ កៅអី |
| ៤.៦ | សំណង់សណ្ឋាគារ | ≥ ៦០ បន្ទប់ |
| ៤.៧ | សំណង់សណ្ឋាគារតំបន់ឆ្នេរ | ≥ ៤០ បន្ទប់ |
| ៤.៨ | សំណង់ផ្លូវជាតិ | ≥ 100 គ.ម |
| ៤.៩ | សំណង់ផ្លូវដែក | គ្រប់ទំហំ |
| ៤.១០ | សំណង់កំពង់ផែ | គ្រប់ទំហំ |

| | | |
|---|---|---|
| ៤.១១ | សំណង់អាកាសយានដ្ឋាន | គ្រប់ទំហំ |
| ៤.១២ | ការបូមភក់ - ល្បប់ | ≥ ៥០.០០០ ម$^{៣}$ |
| ៤.១៣ | កន្លែងចាក់សំរាមទីក្រុង | ≥ ប្រជាជន ២០០.០០០នាក់ |

# ឧបសម្ព័ន្ធទី ៥

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៩៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## វិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលលើនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៦

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសំរាប់គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ ទាក់ទងនឹង ៖

- ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ
- ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ
- ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ២.-**

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ មានដូចខាងក្រោម ៖

១- រាជរដ្ឋាភិបាល គឺជាអ្នកគ្រប់គ្រងរាល់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងរបស់នីតិបុគ្គលសាធារណៈ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការលក់ ការដូរ និងការជួល នូវទ្រព្យសម្បត្តិរបស់រដ្ឋ។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរាយការណ៍អំពីលទ្ធផលនៃការជួល ការលក់ និងការដូរចលនទ្រព្យ និងអចលនទ្រព្យ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ជូនរាជរដ្ឋាភិបាល ។

២- ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ដែលកំពុងកាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្មទ្រព្យសម្បត្តិរបស់រដ្ឋ ជាអាជ្ញាធរកាន់កាប់ប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋ

នៅក្នុងន័យនៃអនុក្រឹត្យនេះ ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានសមត្ថកិច្ចត្រឹមតែប្រើប្រាស់ ថែរក្សា និងស្នើសុំ លក់ ដូរ ឬជួល ។

៣- ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈ ត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធីដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៤- ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈ អាចត្រូវបានលក់ ដូរ ជួល ឬផ្តល់ឱ្យជាសម្បទានផ្សេងទៀតបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ ។ លក្ខខណ្ឌ និងនីតិវិធីនៃការលក់ ការដូរ និងការជួលទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុក្រឹត្យនេះ ។ ចំណែកឯលក្ខខណ្ឌ និងនីតិវិធីនៃការធ្វើសម្បទានទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក ។

## មាត្រា ៣.-

ទ្រព្យសម្បត្តិរបស់រដ្ឋ រួមមានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។ ទ្រព្យសម្បត្តិទាំងនេះអាចជាចលនទ្រព្យ និងអចលនទ្រព្យ ។ ទ្រព្យសម្បត្តិរបស់រដ្ឋ សំដៅលើទ្រព្យសម្បត្តិទាំងឡាយ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយ ដែលរដ្ឋប្រគល់ទៅឱ្យនីតិបុគ្គលសាធារណៈដទៃទៀត កាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្ម ។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ គឺមានទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋ ក្រៅពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចបានកំណត់ក្នុងមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ព្រមទាំងមាត្រា ១២ និងមាត្រា ១៥ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ។

## មាត្រា ៤.-

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងអស់ រួមទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋ របស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃការជួល ការលក់ និងការដូរបាន ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ក៏ដូចជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈដទៃទៀត មិនអាចជាកម្មវត្ថុនៃការលក់ ការដូរ ឬការផ្ទេរកម្មសិទ្ធិណាមួយបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងនេះ អាចជាកម្មវត្ថុនៃការជួលបានតែក្នុងលក្ខខណ្ឌ និងនីតិវិធីដែលមានបញ្ញត្តិនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី ២

## ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ

**មាត្រា ៥.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ រួមមានចលនទ្រព្យ និងអចលនទ្រព្យ ទាំងអស់ដែលស្ថិតនៅក្រោមអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជា ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត។

**មាត្រា ៦.-**

ការធ្វើបញ្ជីសារពើភ័ណ្ឌ ចែកចេញជាបួនថ្នាក់ រួមមាន ÷

១- ថ្នាក់កណ្តាល ឬថ្នាក់ក្រសួង ស្ថាប័ន

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋដែលកាន់កាប់ដោយក្រសួង ស្ថាប័ន ត្រូវបង្កើតឡើង ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម ÷

- ថ្នាក់ដឹកនាំក្រសួងស្ថាប័ន ជាប្រធាន
- ប្រធាននាយកដ្ឋានជំនាញពាក់ព័ន្ធ ជាសមាជិក ។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ ដែលបានរៀបចំរួច។

២- ថ្នាក់មន្ទីរជំនាញតាមខេត្ត ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម ÷

- ប្រធានមន្ទីរជំនាញសាមីដែលទទួលខុសត្រូវអង្គភាពប្រើប្រាស់ ជាប្រធាន
- ប្រធានការិយាល័យប្រើប្រាស់នៃមន្ទីរជំនាញ ជាសមាជិក
- ប្រធានការិយាល័យប្រើប្រាស់ តាមស្រុកខណ្ឌ ជាសមាជិក។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវ លើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង ព្រមទាំងមានការឯកភាពពីអភិបាល ខេត្ត ក្រុង ។

៣- ថ្នាក់ខេត្ត ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង រួមមានសមាជិកដូចខាងក្រោម ÷

ក. សាលាខេត្ត ក្រុង :

- នាយខុទ្ទកាល័យ ឬប្រធានក្រុមហិរញ្ញវត្ថុ ជាប្រធាន
- គ្រប់ប្រធានការិយាល័យផ្ទៃក្នុងរបស់សាលាខេត្ត ក្រុង ជាសមាជិក ។

ខ. សាលាស្រុក ខណ្ឌ :

- អភិបាលស្រុក ខណ្ឌ ជាប្រធាន
- ប្រធានការិយាល័យផ្ទៃក្នុង- ជាសមាជិក
- មេឃុំ- ចៅសង្កាត់ ជាសមាជិក ។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង ព្រមទាំងមានការឯកភាពពីអភិបាលខេត្ត ក្រុង ។

៤- ថ្នាក់នីតិបុគ្គលសាធារណៈដទៃទៀត

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតឡើងដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិក ដូចខាងក្រោម ÷

- ប្រធានអង្គភាព ជាប្រធាន
- ប្រធានផ្នែកជំនាញពាក់ព័ន្ធ ជាសមាជិក

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ ដែលបានរៀបចំរួច ។

**មាត្រា ៧.-**

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាអ្នកជំរុញ និងណែនាំដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ឱ្យរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធីដែលមានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវរួចរាល់ និងផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ យ៉ាងយូរនៅចុងត្រីមាសទី ១ នៃឆ្នាំបន្ទាប់ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសំរេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិរបស់រដ្ឋចូលក្នុងបញ្ជីសារពើភ័ណ្ឌ ។

រាល់បញ្ជីសារពើភ័ណ្ឌដែលបានរៀបចំរួចរាល់ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវផ្តល់ចំនួនពីរច្បាប់ ជូន ដល់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីតំកល់ទុក និងតាមដាន ។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរាយការណ៍ជាទៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៣
## ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ
### ផ្នែកទី ១
### ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ៨.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យ-សម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនោះ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ៩.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួលនោះ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទីផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួន ជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ គណៈកម្មការវាយតម្លៃនេះត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួលនោះ ។

**មាត្រា ១០.-**

ការជូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវរៀបចំធ្វើឡើង ក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិដែលនឹងដាក់ជូល រាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ។ ក្នុងករណីចាំបាច់ ត្រូវមានការសម្រេចជាមុនពីប្រមុខរាជរដ្ឋាភិបាល ។

នីតិវិធីលំអិតនៃការដេញថ្លៃ និងការចរចា ពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១១.-**

ការជូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការជូលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១២.-**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គល ក៏រិតជាតិ ឬអន្តរជាតិចាប់ពី ២ ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវជូល ។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព :

១- ប្រកួតប្រជែងដោយចំហ ជាលក្ខណៈជាតិ ឬអន្តរជាតិ

២- ប្រកួតប្រជែងដោយផ្ទាល់មាត់ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

**មាត្រា ១៣.-**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម ÷

១- ការដេញថ្លៃមិនទទួលបានលទ្ធផល

២- លក្ខណៈពិសេសនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលតំរូវឱ្យអ្នកជូលត្រូវបំពេញបន្ថែមនូវលក្ខខណ្ឌចាំបាច់ផ្សេងៗទៀត ។

៣- មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំជូលតែមួយ ។

មាត្រា ១៤ .-

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការជាស្ថាពរ ដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ មានរយៈពេលយ៉ាងយូរ ៣ (បី) ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវ ចុះកិច្ចសន្យាជួល ដើម្បីរៀបចំនូវសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចបន្តសាជាថ្មីបានមួយលើក ទៀតដែលមានរយៈពេលយ៉ាងយូរ ៣ (បី) ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់ ។ ក្នុងករណីអ្នកដេញថ្លៃបានមិនព្រមចរចា ពិភាក្សា រៀបចំកិច្ចសន្យាជួល តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា លុះត្រាតែលក្ខខណ្ឌទាំងអស់នៃសេចក្តីព្រាងកិច្ចសន្យាត្រូវ បានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសំរួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រង ទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ យ៉ាងយូរ ក្រោយពីទទួលបានពីអាជ្ញាធរ កាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ។

កិច្ចសន្យាត្រូវចែងអំពីលក្ខខណ្ឌចាំបាច់ដែលមានជាអាទិ៍ ÷

១- ការកំណត់ថ្លៃឈ្នួល និងការបង់ថ្លៃឈ្នួល ដោយគិតតាមខែ ត្រីមាស ឬ ឆ្នាំ តាមការព្រមព្រៀង រវាងភាគីនៃកិច្ចសន្យា ។

២- ក្នុងករណីបង់ថ្លៃឈ្នួលយឺតយ៉ាវ អ្នកទទួលជួលត្រូវទទួលការពិន័យ ២ (ពីរ) ភាគរយក្នុងមួយខែ លើថ្លៃឈ្នួល ដែលត្រូវបង់តាមខែ ត្រីមាស ឬ ឆ្នាំ ចាប់ពីរយៈពេល ៦០ (ហុកសិប) ថ្ងៃ ក្រោយការកំណត់ តទៅ។ ប្រាក់ពិន័យនេះ ត្រូវគណនាតាមរូបមន្តការប្រាក់សមាស។

៣- ក្នុងករណីខកខានបង់ថ្លៃឈ្នួលក្នុងរយៈពេលសរុប ៦ (ប្រាំមួយ) ខែ អាជ្ញាធរកាន់កាប់ទ្រព្យ សម្បត្តិរបស់រដ្ឋត្រូវលុបកិច្ចសន្យា និងត្រូវអនុវត្តតាមផ្លូវច្បាប់ជាធរមាន បន្ទាប់ពីមានការយល់ព្រមពីអាជ្ញាធរ គ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ ក្នុងករណីនេះ ប្រសិនបើអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមិនអាចអនុវត្ត បានទេ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋនឹងចាត់វិធានការ ក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីលុបកិច្ចសន្យា និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

កិច្ចសន្យាជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយណា ដែលមិនគោរពតាមនីតិវិធី និងមិនចែងនូវ លក្ខខណ្ឌចាំបាច់ដូចខាងលើនេះ ត្រូវចាត់ទុកជាមោឃៈ។

## ផ្នែកទី ២

## ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

**មាត្រា ១៥.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិសាធារណៈនោះ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ១៦.-**

ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម ÷

១- ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនត្រូវធ្វើឱ្យមានការកែប្រែទិសដៅនៃការប្រើប្រាស់ ឬធ្វើឱ្យមានការខូចខាតដល់ទ្រព្យសម្បត្តិទាំងនោះឡើយ ។

២- ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនត្រូវមានការប៉ះពាល់ ឬធ្វើឱ្យផ្លាស់ប្តូរដល់មុខងារបំរើសេវាសាធារណៈរបស់ទ្រព្យសម្បត្តិទាំងនោះឡើយ ។

**មាត្រា ១៧.-**

ក្រោយពីទទួលបានការអនុញ្ញាតពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចរៀបចំដំណើរការនៃការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនេះ ទៅតាមនីតិវិធីដូចដែលកំណត់នៅក្នុងផ្នែកទី២ នៃជំពូកនេះ ។

**មាត្រា ១៨.-**

កិច្ចសន្យាជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចមានរយៈពេលលើសពី ១៥ (ដប់ប្រាំ) ឆ្នាំឡើយ ។ កិច្ចសន្យានេះធ្វើឡើងក្រោមរូបភាពជាលិខិតអនុញ្ញាតកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលមានលក្ខណៈជាបណ្តោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបានគ្រប់ពេលវេលា ក្នុងបំណងការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងបំរើប្រយោជន៍សាធារណៈ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានភារកិច្ចរៀបចំសៀវភៅបន្ទុកដែលកំណត់អំពីលក្ខខណ្ឌផ្សេងៗនៃការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ ។

## ផ្នែកទី ៣

## ការកែសម្រួលបំពេញបន្ថែមលើកិច្ចសន្យាជួល និងការបង់ចំណូល

**មាត្រា ១៩.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលជាភាគីនៃកិច្ចសន្យាជួលមានរយៈពេល ៩ (ប្រាំបួន) ខែ យ៉ាងយូរបំផុត ត្រូវធ្វើការកែសម្រួលលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរបស់រដ្ឋទាំងឡាយ ដែលបានធ្វើឡើងមុនអនុក្រឹត្យនេះចូលជាធរមាន ដោយរៀបចំបន្ថែមនូវល័ក្ខខ័ណ្ឌចាំបាច់ដូចដែលមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០.-**

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុន នៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀត តាមការកំណត់របស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤

## ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ត្រូវអនុវត្តចំពោះការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលកំពុងស្ថិតក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ទាំងអចលនទ្រព្យ និងចលនទ្រព្យ ។

**មាត្រា ២២.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ជាអ្នកលើកសំណើសុំលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ហើយត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរដ្ឋនេះ ដែលជាកម្មវត្ថុនៃការលក់ទៅឱ្យភាគីម្ខាងទៀត ដោយភ្ជាប់ឯកសារពាក់ព័ន្ធទាំងអស់នេះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ២៣.-**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៤.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការលក់នោះ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទីផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួនជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ គណៈកម្មការវាយតម្លៃនេះ ត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យ សម្បត្តិរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការលក់នោះ ។

**មាត្រា ២៥.-**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវរៀបចំធ្វើឡើងក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ដូចករណីនៃការជួលដែរ ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការលក់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ។ ក្នុងករណីចាំបាច់ត្រូវមានការសម្រេចជាមុនពីរាជរដ្ឋាភិបាល ។

នីតិវិធីលម្អិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៦.-**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គលកំរិតជាតិ ឬអន្តរជាតិ ចាប់ពី ២ (ពីរ) ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវលក់ ។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព :

១-ប្រកួតប្រជែងដោយចំហ ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

២-ប្រកួតប្រជែងដោយផ្ទាល់មាត់ ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

**មាត្រា ២៧.-**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម ÷

១-បើការដេញថ្លៃមិនទទួលបានលទ្ធផល ។

២-មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំទិញតែមួយ ។

៣-អ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះស្នើសុំទិញពីរដ្ឋ ក្នុងករណីអ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះបានចំណាយទុនវិនិយោគបានយ៉ាងតិចចំនួន ៣០ (សាមសិប)ភាគរយនៃគម្រោងវិនិយោគ ឬក្នុងករណីដែលរដ្ឋបានផ្តល់មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធដែលមានរួចស្រេច ហើយគម្រោងនោះបានដំណើរការរយៈពេល ១(មួយ) ឆ្នាំ យ៉ាងតិច ។

**មាត្រា ២៨.-**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃ ដែលទទួលស្គាល់ជាផ្លូវការជាស្ថាពរពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាលហើយនោះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ សម្រាប់ពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាលក់-ទិញ ដើម្បីរៀបចំសេចក្តីព្រាងកិច្ចសន្យានោះ ។ រយៈពេលនេះអាចពន្យាជូនបានមួយលើកទៀត ដែលរយៈពេលយ៉ាងយូរ ៣ (បី)ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងជាការចាំបាច់ ។ ក្នុងករណីអ្នកដេញថ្លៃមិនព្រមចរចាពិភាក្សារៀបចំកិច្ចសន្យាទិញ-លក់តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសចូលថវិការដ្ឋ ។

បន្ទាប់ពីមានការព្រមព្រៀងលើរាល់លក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យា រវាងភាគីកិច្ចសន្យា និងក្រោយពីទទួលបានការពិនិត្យ និងកែសម្រួលពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋរួចរាល់ ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា ។

**មាត្រា ២៩.-**

ចំណូលដែលបានមកពីការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលមេរេទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣០.-**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនភាគីឯកជនបាន អាចធ្វើទៅបានលុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ អំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចប់សព្វគ្រប់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត តាមកំណត់ច្បាប់ ។

## ជំពូកទី ៥
## ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ៣១.-**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ គឺជាការផ្ទេរកម្មសិទ្ធិទៅវិញទៅមករវាងភាគីឯកជន និងភាគីរដ្ឋ ។

ការដូរធ្វើឡើងក្នុងគោលបំណងដោះស្រាយទីកន្លែងបំពេញការងារ រៀបចំតំបន់រដ្ឋបាលឱ្យបានសមស្របទៅតាមតម្រូវការជាក់ស្ដែង និងតាមទិន្នាការអភិវឌ្ឍន៍ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចស្នើដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយ ដែលរួមមានចលនទ្រព្យ និងអចលនទ្រព្យ ដើម្បីបានមកវិញនូវទ្រព្យសម្បត្តិថ្មីសមស្រប ដែលផ្ដល់ឱ្យដោយភាគីឯកជន ។

**មាត្រា ៣២.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការដូរជាមួយនឹងទ្រព្យសម្បត្តិដែលផ្ដល់ដោយឯកជន មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ៣៣.-**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣៤.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដោយមានការចូលរួមពីតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរនោះ ស្របតាមគោលការណ៍បច្ចេកទេស និងតម្លៃទីផ្សារ ។

មាត្រា ៣៥.-

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាមួយនឹងទ្រព្យសម្បត្តិរបស់ភាគីឯកជន ត្រូវប្រព្រឹត្តិតាមរូបភាពដេញថ្លៃជាសាធារណៈ ឬចរចាពិគ្រោះថ្លៃ ទៅតាមនីតិវិធីដូចដែលមានចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃអនុក្រឹត្យនេះ។

ភាគីឯកជនដែលចូលរួមដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ត្រូវមានទ្រព្យសម្បត្តិសមស្រប ដើម្បីជាថ្នូរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

ល័ក្ខខ័ណ្ឌ និងការទូទាត់តម្លៃនៃការដូរ ត្រូវកំណត់ឡើងដោយសៀវភៅបន្ទុកមួយ ដែលត្រូវរៀបចំដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអាជ្ញាធរនេះត្រូវផ្ញើសៀវភៅបន្ទុកនោះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

មាត្រា ៣៦.-

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវពិនិត្យផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចារពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវស្នើសុំការសម្រេចជាមុនពីរាជរដ្ឋាភិបាល។

នីតិវិធីលម្អិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣៧.-

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការស្ថាពរដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាដូរ ដើម្បីរៀបចំសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចពន្យាជូនបានមួយលើកទៀតដែលមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់។ ក្នុងករណីអ្នកដេញថ្លៃបាន មិនព្រមចរចាពិភាក្សា រៀបចំកិច្ចសន្យាដូរតាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរិបអូសបង់ចូលថវិការរដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា លុះត្រាតែលក្ខខណ្ឌទាំងអស់នៃសេចក្តីព្រាងកិច្ចសន្យា ត្រូវបានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសម្រួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន ។

**មាត្រា ៣៨.-**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនឯកជន អាចធ្វើទៅបាន លុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ អំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចរចាដោយផ្ទាល់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត ។

**មាត្រា ៣៩.-**

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ
## ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគ

**មាត្រា ៤០.-**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ត្រូវធ្វើឡើងតាមគោលការណ៍ និងបទប្បញ្ញត្តិដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ។

វិធាន និងនីតិវិធីនៃការធ្វើអនុបយោគ ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៤១.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានតួនាទីធ្វើការអង្កេតជាសាធារណៈ និងធ្វើរបាយការណ៍បញ្ជាក់អំពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលបានបាត់បង់លក្ខណៈសម្បត្តិរបស់ខ្លួន ក្នុងការបម្រើផលប្រយោជន៍សាធារណៈ តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ហើយស្នើសុំធ្វើអនុបយោគ ដោយមានភ្ជាប់សំណុំឯកសារទាំងអស់

មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់ជូនរាជរដ្ឋាភិបាលសម្រេច តាមរយៈអនុក្រឹត្យ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ៤២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ✎

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៤៣
- ឯកសារ- កាលប្បវត្តិ

# ឧបសម្ព័ន្ធទី ៦

## ឧបសម្ព័ន្ធទី៦

ទិដ្ឋភាពផ្សារកំពង់ជ្រៃ ខេត្តតាកែវ ក្នុងឆ្នាំ២០១៧ ក្រោយពីធ្វើអស្សាមិករណ៍



**ឧបសម្ព័ន្ធទី៦**

ទិដ្ឋភាពផ្សារកំពង់ជ្រៃ ខេត្តតាកែវ ក្នុងឆ្នាំ២០១៧ ក្រោយពីធ្វើអស្សាមិករណ៍



# ឧបសម្ព័ន្ធទី ៧

**ឧបសម្ព័ន្ធទី៧**

គម្រោងសាងសង់ស្លាបខាងជើងស្ពានព្រែកក្ដាម នៅភូមិទួលងោក ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល



**ឧបសម្ព័ន្ធទី៧**

គម្រោងសាងសង់ស្លាបខាងជើងស្ពានព្រែកក្តាម នៅភូមិទួលងោក ឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្តាល



# ឧបសម្ព័ន្ធទី ៨

**ឧបសម្ព័ន្ធទី៨**

ស្ថានីយ៍ប្រេងឥន្ធនៈមួយកន្លែង ស្ថិតក្នុងគម្រោងពង្រីកផ្លូវ និងសាងសង់ស្ពាន
អាកាសដែលធ្វើនៅសង្កាត់ចោមចៅ រាជធានីភ្នំពេញ



**ឧបសម្ព័ន្ធទី៨**

ស្ថានីយ៍ប្រេងឥន្ធនៈមួយកន្លែង ស្ថិតក្នុងគម្រោងពង្រីកផ្លូវ និងសាងសង់ស្ពាន

អាកាសដែលធ្វើនៅសង្កាត់ចោមចៅ រាជធានីភ្នំពេញ



# ឧបសម្ព័ន្ធទី ៩

**ឧបសម្ព័ន្ធទី៩**

កំណាត់ផ្លូវដែកមួយដែលលាតសន្ធឹងពីផ្លូវជាតិលេខ៥ កាត់តាមសង្កាត់មួយ

ចំនួនក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ



# ឧបសម្ព័ន្ធទី ១០

## ឧបសម្ព័ន្ធទី១០

ព្រះវិហារអាល់សឺកាល (ព្រះវិហារអ៊ីស្លាម) មានទីតាំងនៅក្បែរតំបន់បឹងកក់



# ឧបសម្ព័ន្ធទី ១១

## ឧបសម្ព័ន្ធទី១១

### គម្រោងអភិវឌ្ឍនៅអគារប៊ូឌីញ



**ឧបសម្ព័ន្ធទី១១**

គម្រោងអភិវឌ្ឍនៅអគារប៊ូឌីញ

